# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0139**

## សម្ភាសន៍ជាមួយឈ្មោះ យ៉ែម គីមរស់ ភេទស្រី អាយុ៥៦ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ “កងចល័តទំនប់ត្រពាំងថ្ម”

## សព្វថ្ងៃរស់នៅភូមិប៉ោយសំរោង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ

## ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ១:០៨:២១

## ២៨ទំព័រ

វណ្ណៈ : ឥឡូវថ្ងៃហ្នឹង ថ្ងៃទី១៦ ខែ ៦ ឆ្នាំ ២០១១ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំមកដល់ភូមិឃុំមីង គឺចង់ដឹងរឿងរ៉ាវទុកជាប្រវត្តិសាស្រ្ត ដើម្បីឲ្យក្មេងជំនាន់ក្រោយបានរៀនបានសូត្រណាមីង ផ្តោតសំខាន់ទៅលើទំនប់អាងត្រពាំងថ្មតែម្តង ព្រោះថាប្រជាជនបងប្អូនយើងទាំងចាស់ទាំងថ្មីហ្នឹង ជួបការលំបាក មានស្លាប់មានអីណាមីងណា ហើសម្ភាសន៍បែបហ្នឹង បន្តិចទៀតនេះខ្ញុំសួរមីងតាំងពីដើមទៅ ។ បាទ! ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរមីង?

គីមរស់ : ខ្ញុំឈ្មោះ យ៉ែម គីមរស់ ។

វណ្ណៈ: ធ្វើគ្រូ នាយការអនុវិទ្យាល័យព្រះនេត្រព្រះ ។

វណ្ណៈ : សព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

គីមរស់ : ៥៦ ហើយ ។

វណ្ណៈ : គ្រួសារមីងគាត់ឈ្មោះអីដែរ?

គីមរស់ : គ្រួសារខ្ញុំឈ្មោះ ពេជ្រ វណ្ណា ហៅ លោកគ្រូ សារ៉ាន់ ។

វណ្ណៈ : ពូអាយុប៉ុន្មានហើយ?

វណ្ណា : អាយុ ៥៩ឆ្នាំ ។

វណ្ណៈ : មីងរាល់ថ្ងៃជានាយកសាលា?

គីមរស់ : នាយការអនុវិទ្យាល័យព្រះនេត្រព្រះ ។

វណ្ណៈ : កូនចៅប៉ុន្មានដែរ?

គីមរស់ : អត់! មានតែចៅ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

វណ្ណៈ ៖ អីចឹងដូចថាស្រុកកំណើតកើតជា?

គឹមរស់ ៖ កើតនៅភូមិហ្នឹងឯង ប៉ៅយសំរោង ហ្នឹងឯង ។

វណ្ណៈ ៖ ឃុំព្រះនេត្រព្រះ!

គឹមរស់ ៖ ឃុំព្រះនេត្រព្រះ ។

វណ្ណៈ ៖ ស្រុកព្រះនេត្រព្រះ!

គឹមរស់ ៖ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ៖ ពីមុនខេត្តបាត់ដំបង?

គឹមរស់ ៖ ចា៎! ពីមុនខេត្តបាត់ដំបូង ។

វណ្ណៈ ៖ ខ្ញុំចង់ដឹង ឪពុកមីងគាត់ឈ្មោះអីដែរ?

គឹមរស់ ៖ ឪពុកខ្ញុំឈ្មោះ យែម ញឹប ។

វណ្ណៈ ៖ ម្តាយ?

គឹមរស់ ៖ ម្តាយឈ្មោះ ចិ លឿន ។

វណ្ណៈ ៖ សព្វថ្ងៃគាត់ស្លាប់ឬក៏នៅរស់?

គឹមរស់ ៖ សព្វថ្ងៃនៅតែម្តាយ ។

វណ្ណៈ ៖ ចុះបងប្អូនមីងមានប៉ុន្មានដែរ?

គឹមរស់ ៖ បងប្អូនខ្ញុំ ៩នាក់ ។

វណ្ណៈ ៖ នៅសល់ប៉ុន្មានសព្វថ្ងៃ?

គឹមរស់ ៖ សព្វថ្ងៃនៅសល់៦ ។

វណ្ណៈ ៖ ប៉ុន្មានទៀតស្លាប់ក្រោយ៧៩ ឬក្នុងសម័យខ្មែរក្រហម?

គឹមរស់ ៖ ចា៎! ក្រោយសម័យខ្មែរក្រហម ក្មេងៗតូចៗនោះ ។

វណ្ណាៈ ចុះឯងងាប់អស់៣!

គឹមរស់ ៖ អស់៣ អាគុណ, អាណាន, អាណេត ។

វណ្ណៈ ៖ ហើមីងកាលពីដើម មីងរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

គឹមរស់ ៖ ខ្ញុំរៀនដល់ថ្នាក់ទី១ ។

វណ្ណៈ ៖ ថ្នាក់ទី១ ពីសង្គមឬ?

គឹមរស់ ៖ ចា៎! ទៅរៀននៅស្វាយរហូត ។

វណ្ណៈ ៖ មីងកាលបឋមសិក្សាមីងរៀននៅឯណាដែរ?

គីមរស់ ៖ ព្រះនេត្រព្រះ ។ រៀនទល់ថ្ងៃ ១៧ មេសា គេវ៉ៃបែក ដល់ថ្ងៃ២០ចេញមកណេះ ។

វណ្ណៈ ៖ បាទ! រៀននៅព្រះនេត្រព្រះចប់...

គីមរស់ ៖ ចា៎! ចប់ថ្នាក់នៅនេះ ទៅរៀននៅស្វាយ ។

វណ្ណៈ ៖ នៅស្វាយរហូត?

គីមរស់ ៖ ចា៎! នៅស្រុកសេរីសោភ័ណរហូត ។

វណ្ណៈ ៖ រហូតដល់ឆ្នាំណាបានមីងឈប់?

គីមរស់ ៖ រហូតដល់ឆ្នាំ៧៥ ដែលអាពតវ៉ៃបែក ១៧មេសា ។

វណ្ណៈ ៖ សម័យ៧០ ដែលរដ្ឋប្រហារហើយមីងនៅឆ្លៀតបានរៀនដែរ?

គីមរស់ ៖ ចា៎! ចុះធ្វើរដ្ឋប្រហារបានរៀននៅនោះ នៅរៀនរហូតទល់៧៥ ទល់តែចប់៧៥បានមកផ្ទះ មកផ្ទះនោះនៅជាមួយគេបានតែ២ ទៅ ៣ថ្ងៃទេ ខ្ញុំនោះយើងកូនសិស្សនៅជាមួយគេ មិនបាននៅក្នុងភូមិហ្នឹងទៀត គេឲ្យទៅចល័តរហូត ខ្ញុំលើកទំនប់រហូត ។

វណ្ណៈ ៖ អីចឹង៧៥ត្រឡប់ចូលភូមិវិញឬ?

គីមរស់ ៖ ចា៎!

វណ្ណៈ ៖ ត្រឡប់ចូលភូមិវិញអីចឹង ដូចថាមីងមកដល់ភូមិភ្លាម មីងនៅជួយធ្វើការឪពុកម្ដាយ ឬក៏ទៅជាកងចល័ត កងអីហើយ?

គីមរស់ ៖ អត់ទេ! មកដល់ភូមិភ្លាម មកនៅផ្ទះបានប៉ុន្មាន២, ៣ ថ្ងៃ គេឲ្យជម្លៀសចេញទៅនៅស្ទឹងជិតដូនប្រែង ចេញទៅណុះម្ដងបាន៣ថ្ងៃគេឲ្យចូលមកក្នុងភូមិវិញ ដល់នៅក្នុងភូមិបាន ៣, ៤ ថ្ងៃទៀត គេឲ្យយើងចេញ ទៅម្ដងនេះទៀតគេអត់មានឲ្យយើងយកអីទេ កាលលើកមុនមានបានយកនេះយកនោះទៅបានខ្លះ ដល់ចេញក្រោយនេះគេដេញបន្ទាន់រឹបៗទៅ យើងទៅ ។

វណ្ណៈ ៖ ជម្លៀសទៅភូមិដូនប្រែង?

គីមរស់ ៖ ចា៎! ទៅតាមដងស្ទឹងជិតដូនប្រែង ។ វាលណុះ គេមិនឲ្យទៅនៅភូមិទេ នៅវាល ។

វណ្ណៈ ៖ ពេលណាត្រឡប់ទៅភូមិវិញ?

គីមរស់ ៖ បាន ៤,៥ ថ្ងៃ គេឲ្យត្រឡប់ចូលភូមិវិញ ។

វណ្ណៈ ៖ ចូលភូមិវិញធ្វើម៉េចទៀតទៅ?

គីមរស់ ៖ ឲ្យចូលភូមិវិញបាន៤,៥ ថ្ងៃ បានគេឲ្យយើងចេញទៅម្ដងទៀត លើកនេះគេអត់ឲ្យយើងយកអីទៅទេ ឲ្យយើងចេញជាប្រញាប់ៗ ទៅខ្លះក៏បានស្អី ខ្លះក៏មិនបាន ចោលទៅផ្ទះ

ទាំងអស់ទៅ ដល់ទៅនៅទៅគេឲ្យយើងទៅនៅហ្នឹងស្រែះ ដល់ពេលនេះហ្នឹងហើយដែលគេជម្លៀសចេញទៅ ហីគេសម្លាប់មនុស្សបណ្តើរៗ យើងចេញទៅគេសម្លាប់ ។

វណ្ណៈ : ឆ្នាំ៧៥ ហ្នឹងឬ?

គឹមរស់ : ចា៎!

វណ្ណៈ : ៧៥ ហ្នឹង គេសម្លាប់របៀបម៉េចទៅមីង បើតាមមីង គេសម្លាប់ហ្នុង គេមើលថាយ៉ាងម៉េច ថាអ្នកហ្នុងយ៉ាងម៉េច បានត្រូវសម្លាប់?

គឹមរស់ : គេសម្លាប់ហ្នុង ដូចក្រុមគ្រួសារមួយអាផ្ទះក្បឿងនៅខាងស្រែះ ឈ្មោះចែខុមៗ ហ្នុងឪពុកម្តាយគេសម្លាប់អស់ទាំងក្រុមគ្រួសារ ។

វណ្ណៈ : ចុះសម្លាប់គាត់ដោយសាររឿងអី?

គឹមរស់ : គេសម្លាប់ម៉ាគ្រួសារហ្នឹង ឪពុកគាត់ធ្វើមេភូមិ ។

វណ្ណៈ : ឪពុកមេភូមិ លន់ នល់ ឬ?

គឹមរស់ : ចា៎! ឪពុកមេភូមិសម័យ លន់ នល់ ហីកូនប្រសារកាត់លោក រី នោះទាហានសក្តិ ៥ អីចឹងណា ដល់គេជម្លៀសចេញទៅស្រែះទៅ ដល់យើងដល់គោកស្រុកនោះ បានទៅដល់ដែរទេ!

វណ្ណៈ : មិនទាន់ទៅទេ ។

គឹមរស់ : ដល់គោកស្រុកនោះមានដើមពោធិ៍ ដើមផ្លូវ មិនមែនទំនប់អីចេះទេណា អាត្រង់ហ្នុងក៏ ខ្ញុំលើកដែរណា អាខាងកើតផ្លូវទៅស្រែះក៏ខ្ញុំលើកដែរ ទំនប់ហ្នឹងនេះ ។

វណ្ណៈ : ចុះធ្វើម៉េចបានគេស្រាវជ្រាវ ដឹងក្លាមៗអីចឹង?

គឹមរស់ : ដែលមិនស្គាល់ឬ ពួកអាពត នៅក្បែរៗយើង ពួកស៊ីងកំបុត ស៊ីងអីនេះ ស្គាល់ហើយអ្នកភូមិនេះ គេស្គាល់បានគេចូលមកទៅ គេជម្លៀសទៅគេចាប់ លោក រី នោះណា គេបាញ់ចោល អាកំពុងយើងបណ្តើរគ្នារអឺនចេញទៅទាំងអស់គ្នាហ្នឹងណា គេចាប់លោក រី ហ្នឹង គេបាញ់ចោលទៅ គេបាញ់ចោលលោក រី ហ្នុងមួយទៅគេ ទៅស្រាវជ្រាវយកឪពុកម្តាយទៀត យកទាំងអស់ឪពុកម្តាយគាត់មានកូនប្រុស កូនស្រី ប្តីប្រពន្ធគាត់នាងសុខាម កូនហ្នុងស្អាតណាស់សាច់សរស្គុះដូចបារាំង ស្អាតនាងនោះ ប្អូនចែខុម នាងនោះពោះគេ នាងនោះយកទៅបាញ់ចោលនៅគល់ត្នោតចង់ផ្អោបអីចឹង យំអង្វរគេ ប្រជាជនខ្លាចឡើងញ័រខ្លួនដូចកូនកណ្តុរហើយពេលនោះ មិនដែលឃើញសេចក្តី ស្លាប់ដូចអីចេះ

យើងការស្លាប់របៀបនោះ គឺថាម្នាក់ៗខ្លោចផ្សារអស់ហើយ ដែលគេបាញ់លោក រី នោះ ផ្កាប់មុខប្រហឹត ។

វណ្ណៈ : ចុះ សុខា នោះគេបាញ់ដែរ?

គឹមរស់ : សុខាម ហ្នឹងក៏គេបាញ់ដែរ ។

វណ្ណៈ : ដែលនោះគេបាញ់ដែរ?

គឹមរស់ : បាញ់ដែរ ហ្នុងគេបាញ់លោក រី មុនណា បានគេចាប់ប្រពន្ធលោក រី ឈ្មោះ ចែខន ឈ្មោះអ៊ី ភឹម អ៊ីលី ប្តីប្រពន្ធគាត់ ហើនិងកូនកម្លោះមួយ កូនក្រមុំមួយ អាហ្នឹង គេចាប់យកទៅបាញ់ចោល ខ្ញុំទៅដល់ស្រែះហើយ ដល់ស្រែះហ្នឹងដើមពោធិ៍ សព្វថ្ងៃ ដើមពោធិ៍នៅធំណាស់ ធំមែនទែន ធំឡើងប្រជាជនម៉ាភូមិច្រកក្រោមបានទាំងអស់ មួយ នៅសព្វថ្ងៃហ្នឹង ទៅដល់ក្រោមដើមពោធិ៍យើងជុំគ្នារទេះអី គោក្របី អាមនុស្សទើបទៅដល់ អាយើងចេញដំណើរ ប្រេះៗទៅក៏ដោយ គេឲ្យឈប់ត្រង់នោះណា ឈប់ក៏ជុំគ្នាទៅ ហើយក៏គេទៅរកចាប់គាត់យកចងទៅវ៉ៃចោលនៅរហាល ម្លោះហើយប្រជាជនម៉ាពេល នោះ គឺថាខ្លាចណាស់ ម្នាក់ៗខ្លាចបាក់ស្បាត ញ័រខ្លួនញ័រប្រាណអស់ គ្រប់គ្នា ។

វណ្ណៈ : ចុះពេលថ្មីៗហ្នុងដែរ ដូចជាប្រធានភូមិ ប្រធានឃុំអីមីងស្គាល់ទេ ភ្លាមៗហ្នុង ឬអត់ទាន់ ស្គាល់ទេ?

គឹមរស់ : កាលហ្នុង មិនទាន់ស្គាល់ទេ ។

វណ្ណៈ : មានពីណាគេដឹកនាំ?

គឹមរស់ : កាលហ្នុងមិនទាន់ស្គាល់ទេ ដល់ឡើងយូបន្តិចទៅ បានដឹងដំណឹងថាអ្នកណាគេអ្នកសម្លាប់ មិនដឹងថាអ្នកណាគេពួកណាទេកាលហ្នុង បាញ់ងាប់អស់ហើយ និយាយទៅក៏គ្មានអីនៅ ។

វណ្ណៈ : ពួកតាក្រក់ តាអីហ្នឹងស្លាប់អស់ហើយ?

គឹមរស់ : ពួកតាក្រក់ តាសន នៅតាតែជនទេ ម៉ាម័យនោះពួកតាក្រក់ តាសន អីហើយ ប៉ុនពួក យោធាដែលសម្លាប់នោះ មិនដឹងពួកណាទេ យើងទៅស្គាល់គេអី សល់តែតាក្រក់ តាសន អី ត្រូវគេវ៉ៃចោលអស់ងាប់អស់ មិនសល់ទេ មានអីនៅងាប់អស់រលីញហើយ គ្មានអ្នក ណានៅមួយទេ ។

វណ្ណៈ : មីងកាលសម័យតាក្រក់ តាសន ហ្នឹងក៏សម្លាប់ប្រជាជនច្រើនដែរមីង?

គឹមរស់ : ចា៎! សម្លាប់ដែរ ប៉ុន្តែ អានោះគ្រាន់តែថាសម្លាប់វាមិនសូវច្រើន ប៉ុណ្ណេះទេ ។

វណ្ណៈ : ក្រោយមកទៀតបានសម្លាប់ច្រើន?

គីមរស់ ៖ ចា៎! ដល់ពួកនិរតីមកនេះបានគេចង់ទាំងខែ្សៗ វាវៃនោះ បានស៉ាប់អស់នោះ សម្លាប់ខ្លាំង សម្លាប់អាឆ្នាំ៧៨ យើងពីឆ្នាំ៧៥ មករហូតដល់៧៧, ៧៨ យើងរស់ធម្មតាទេ មិនសូវអីទេ មានបាយ មានអីស៊ីខ្វះ វាយ៉ាប់ខ្លាំងអាឆ្នាំ៧៨នេះតើ វាយ៉ាប់ខ្លាំង អង្ករមៅឆ្នាំខ្វះ មានអង្ករពីរ បី គ្រាប់នោះ ហ្នឹងបានយើងយ៉ាប់ខ្លាំងជាងគេ អាជិតចប់នេះ ឆ្នាំ៧៨នេះ បានវាខ្លាំងខ្លា ហើយអាវៃចោលនេះក៏វៃចោលចុងឆ្នាំ៧៧ ចូល ៧៨ នេះដែរ ៧៨ ខែនេះឯង វស្សាអីចេះឯង ភ្លៀងប្រេះៗអីចឹងចាប់វៃចោល វៃខ្លាំងអា៧៨ នេះឯង វៃខ្លាំងមែនអាឆ្នាំ៧៨ហ្នឹងហើយ ។

វណ្ណៈ ៖ អីចឹងខ្ញុំចង់សួរ មានការជម្លៀសហ្នឹងការសម្លាប់ទាំងគ្រួសារអីចឹងហើយ ចូលដល់ភូមិវិញហើយណ៎?

គីមរស់ ៖ ចា៎!

វណ្ណៈ ៖ ហីពីណាចាត់មីងទៅកងចល័តកងអីទៀត?

គីមរស់ ៖ កាលហ្នុងយើងអ្នកស្រុកភូមិហ្នុងហើយ ថាគេប្រធាន គេក្តាប់អីចឹងទៅណា រៀបចំភូមិអីចឹងទៅ?

វណ្ណៈ ៖ មេភូមិពីណាគេ?

គីមរស់ ៖ តាឆន តាអីស៉ាប់អស់ហើយ មិនមាននៅសល់ទេ ។

វណ្ណៈ ៖ តាឆន ឲ្យមីងទៅកងចល័តឬ?

គីមរស់ ៖ ចា៎! កាលហ្នុងមិនដឹងជានណាទេ មិនទាន់រៀបចំ តា ឆន ទេ តាឆនមិនទាន់មកទេ គេចាត់តាំងតែក្មាយើងហ្នឹងឯង ។

វណ្ណៈ ៖ មីទៅកងចល័តដំបូងទៅកន្លែងណាដែរ?

គីមរស់ ៖ ព្រៃមាន់ គរ៣ដើម តាមផ្លូវទៅភ្នំស្រុក ។

វណ្ណៈ ៖ ព្រៃមាន់ ដើមគរ៣ដើម?

គីមរស់ ៖ ចា៎!

វណ្ណៈ ៖ ទៅហ្នឹងធ្វើអីមីង?

គីមរស់ ៖ លើកតែទំនប់ ។

វណ្ណៈ ៖ លើកទំនប់ដែរកន្លែងហ្នុង?

គីមរស់ ៖ ចា៎! ទំនប់នៅទល់សព្វថ្ងៃ ។

វណ្ណៈ ៖ ឆ្នាំណាលើកទំនប់ហ្នុង?

គឹមរស់ ៈ ឆ្នាំ៧៥ ហ្នុង ។

វណ្ណៈ ៈ លើកទំនប់នៅដើមគរ៣ដើមហ្នុងគេមានដាក់កំណត់ឲ្យលើកផែនការយ៉ាងម៉េចទេ?

គឹមរស់ ៈ ទេ! អាហ្នុងមិនទាន់មានផែនការទេ ។

វណ្ណៈ ៈ យើងចេះតែលើកតាមធម្មតា?

គឹមរស់ ៈ ចេះតែលើកតាមធម្មតាទៅ ដាក់បង្គីយើងតគ្នាលើកទៅ កាលហ្នុងវាអត់អីទេ តាមធម្មតា ។

វណ្ណៈ ៈ អាហ្នុងខ្ញុំឮគេនិយាយដែរ លើកតគ្នា?

គឹមរស់ ៈ លើកបង្គីរតគ្នា លើកទៅណា ។

វណ្ណៈ ៈ ប៉ុនលឿនដែរ តគ្នាព្រឹបៗ!

គឹមរស់ ៈ ចា៎! គ្នាច្រើន អ្នកកាប់ក៏កាប់ទៅ អ្នកលើកក៏លើកទៅ ដូចថាកម្លាំងវានៅថាមពល វាមានស៊ីគ្រប់គ្រាន់ ពេលនោះវាអត់មាន អត់ស៊ីទេ ពួកចល័តមានស៊ីគ្រប់គ្រាន់ បាយគ្រប់គ្រាន់ ម្ហូបអាហារគេបើកឲ្យស៊ីគ្រប់គ្រាន់ហ្នឹង ត្រីងៀតអីហ្នឹងមាន មិនអត់ទេ ស៊ីបានគ្រប់គ្រាន់ ត្រីឆ្អើរ ត្រីងៀតអីមាន មិនអត់ទេ ស៊ីបានគ្រប់គ្រាន់ មានសេរីភាព ហឺសប្បាយរីករាយគ្រាន់ដែរណា មុនដំបូងវាអត់ទាន់ធ្វើអីដូចជាសម្បាយដែរតើស ទៅនៅដេកជាក្រុម ដាកងដេកជុំគ្នាទៅ ក្រោមតង់ ក្រោមអីទៅ បើពួកខ្ញុំមិនបានមានតង់ទេ ខ្ញុំធ្វើខ្ទម ខ្ទមៗដូចខ្ទមខ្មោចអីចឹង បាំងស្បូវនាំគ្នាត្រសុលដេកបន្តិចទៅ នៅលើកហ្នឹងទៅ ។

វណ្ណៈ ៈ អីចឹងដូចថាមនុស្សនៅលើកទំនប់នៅអាកន្លែងដើមគរបីដើមនោះ មនុស្សប្រហែលប៉ុន្មាននាក់ទៅ រាប់រយ រាប់ពាន់...

គឹមរស់ ៈ ច្រើនណាស់ រាប់រយ រាប់ពាន់នាក់ដែរហ្នុង ច្រើនដែរ ក្នុងម៉ាតំបន់លើកនៅនេះឯង ។

វណ្ណៈ ៈ តំបន់ប៉ុន្មានហ្នឹង?

គឹមរស់ ៈ តំបន់ ៥ ។

វណ្ណៈ ៈ ពេលធ្វើការ ម៉ោងប៉ុន្មានព្រលឹមឡើង ម៉ោងប៉ុន្មានចុះ...

គឹមរស់ ៈ ធ្វើការម៉ោង៧ ។

វណ្ណៈ ៈ ម៉ោងប៉ុន្មានឡើងញុំាបាយ?

គឹមរស់ ៈ ម៉ោង ១១ ។

វណ្ណៈ ៈ ម៉ោង ១១!

គឹមរស់ ៈ ចា៎! ម៉ោង ២ ចុះទៀត ៥ឡើង ។

វណ្ណៈ : ម៉ោង ៥ឡើងវិញ ហើយអត់មានធ្វើការយប់អីទៀតទេ?

គីមរស់ : អត់ទេ!

វណ្ណៈ : ចុះដល់ពេលក្រោយមកទៀត ដល់ឆ្នាំ៧៦អី?

គីមរស់ : ឆ្នាំ៧៦អី ក៏នៅតែលើកទំនប់ លើកតាមភ្លឺគេណា តាមផ្លូវយើងមកពីសៀមរាបហើយ យើងឃើញអាភ្លឺ ខាងចុងអីចេះៗ

វណ្ណៈ : អានេះលើកភ្លឺស្រែវិញ!

គីមរស់ : ចាំ! ភ្លឺធំអីចេះ ទឹកស្មើៗណោះ ហើយចាក់ក្នុងទឹកទៅណា ចាក់ដីទៅ បោចស្មៅ បោច អីមកក្រាលរៀបទៅ ក៏លើកដីបិទទៅកើតជាទំនប់រហូតតាំងពីព្រៃរហូត ដល់រហាល ពេល នោះឯងកំពុងដឹក កំពុងលើកហ្នឹងដែលគេដឹកប្រជាជនថ្មីមកៗ

វណ្ណៈ : ឆ្នាំ៧៦ ប្រជាជនទើបមកដល់ទេ ប្រជាជនថ្មី?

គីមរស់ : ចាំ! ៧៥ទេ មិនមែន៧៦ទេៗ

វណ្ណៈ : ពាក់កណ្តាល៧៥!

គីមរស់ : ចាំ!

វណ្ណៈ : ៧៥,៧៦!

គីមរស់ : ហ្នឹងឯង ៧៥, ៧៦ហ្នឹងឯង វាភ្លេចហើយ អូនឯង ទល់តែមានអ្នករំលឹកបាន ខ្ញុំវា បំភ្លេចចោលដែរណា រឿងប្រវត្តិដូចត់នោះ ខ្ញុំបំភ្លេចចោល ដូច៧៥ អីចឹងហើយៗ

វណ្ណៈ : ប្រជាជនថ្មីចូលមកហ្នឹង យើងប្រជាជនថ្មី ប្រជាជនចាស់ហ្នឹងយើងធ្វើការជាមួយគ្នាដែរ?

គីមរស់ : ៧៥ ខែវស្សាហើយ ខែទឹកជន់ហើយ អាលើកទំនប់តាមនេះ ប្រជាជនថ្មីមកឆ្នាំ៧៥ ហ្នឹងៗ

វណ្ណាៈ ខែ៩ឆ្នាំ៧៥ៗ

គីមរស់ៈ ត្រូវហើយខែមានទឹក ខែវស្សាៗ

វណ្ណៈ : ខែ ៩, ៧៥!

គីមរស់ : ហ្នឹងហើយ អាហ្នឹងដឹកប្រជាជនថ្មីមក ដល់ក្រោយពីនេះមកខ្ញុំនៅចល័តរហូតដែរ ដល់ឆ្នាំ ៧៦បានឲ្យចេញមកភូមិហើយ ហ្វូនៅចល័តតែរហូតហ្នឹងៗ

វណ្ណៈ : ចូលភូមិធ្វើអីទៅ?

គីមរស់ : ចាំ!

វណ្ណៈ : ចូលភូមិវិញធ្វើអីទៅ?

គីមរស់ ៖ ធ្វើជាប្រជាជនធម្មតា ចល័ត នៅនេះមិនបានយូទេ មកភូមិមួយប្រាំវាគេឲ្យទៅទៀតហើយ ក៏ទៅទៀតទៅ មិនដែលបាននៅទេ ចល័តតែរហូតហ្នុង ។

វណ្ណៈ ៖ ដល់ឆ្នាំណាបានមឹងទៅអាងត្រពាំងថ្ម?

គីមរស់ ៖ ឆ្នាំ៧៧បានទៅត្រពាំងថ្ម ។

វណ្ណៈ ៖ ៧៧ ហ្នឹង ពួកនិរតីមកនៅ?

គីមរស់ ៖ ទេ អត់ទេ! និរតីមិនទាន់មកទេ ៧៧ មិនទាន់មកទេ ចុងឆ្នាំ ៧៧ បាននិរតីមក ។

វណ្ណៈ ៖ ប្រហែលប៉ុន្មាន ខែវស្សា ឬ ខែអី?

គីមរស់ ៖ គេខវស្សាដែរ ប្រហែលខែ៧ ខែ៨ ហ្នុងឯង បាននិរតីមក តែយើងទៅលើកទំនប់ ឆ្នាំ៧៧ហ្នុងខែ២ ខែ៣ ខែ៤ ខែ៥ហ្នុងណា ។

វណ្ណៈ ៖ អីចឹងកាលនិរតីមកមឹងដូចថាស្គាល់ដូចថា នៅខាងតំបន់៥ ហ្នឹងពីណាគេគណៈតំបន់ គណៈស្រុក គណៈអី?

គីមរស់ ៖ គណៈតំបន់ បង ហ៊ីង បង ជាល គណៈភូមិភាគ តាញឹម បង ហ៊ីង បង ជាល ចៅហ្វាយស្រុកបង មៅ៉ង បង សំអាត តាវ៉ាល់នេះលើកទំនប់កំបោរ ប៉ុនស្លាប់អស់ហើយ គ្មានអ្នកណានៅរស់ទេ ។

វណ្ណៈ ៖ ចៅហ្វាយស្រុកតាមោង?

គីមរស់ ៖ ចា៎! អនុប្រធានតាសំអាត

វណ្ណាៈ ឆាង នោះទទួលផ្នែកសេដ្ឋកិច្ច ។

វណ្ណៈ ៖ ឆាង!

គីមរស់ ៖ ចា៎!

វណ្ណៈ ៖ ចុះ តាវ៉ាល់!

គីមរស់ ៖ តា វ៉ាល់ ប្រធានទំនប់ ក្តាប់ចល័តទាំងអស់ហើយ ចល័ត លើតាវ៉ាល់ ប៉ុនស្លាប់អស់ហើយ គ្មានសល់ទេ ។

វណ្ណាៈ អគ្គមេបញ្ជាការប្រព័ន្ធទំនប់ប្រឡាយតំបន់៥ ។

វណ្ណៈ ៖ តាវ៉ាល់ហ្នឹងគាត់ទាហានទេអីចឹងបានគាត់អគ្គមេបញ្ជាការគាត់ខាងទាហានទេអីចឹង?

គីមរស់ ៖ គាត់ដឹកនាំលើកទំនប់ហ្នឹង ។

វណ្ណាៈ គាត់អគ្គមេបញ្ជាការប្រព័ន្ធទំនប់ប្រឡាយ អត់មែនអគ្គមេបញ្ជាការយោធាទេណា បានន័យថាត្រួតត្រាចល័តម៉ាតំបន់៥ហ្នឹងលើគាត់ម៉ង...។

វណ្ណៈ ៖ ចុះតាហ៊ីនគាត់ធ្វើអី?

គីមរស់ ៖ តាហ៊ីន ប្រធាន គណៈតំបន់ ។

វណ្ណៈ ៖ តាជាល ក៏តំបន់បន្ទាប់ៗពីតា រស់ ញឹម អីមកដែរ?

គីមរស់ ៖ នែតាញឹម គាត់ភូមិភាគ តាហ៊ីន តំបន់ តាជាល អនុប្រធាន ស្គាល់តែតាញឹមហ្នឹងគាត់មកនេះ ។

វណ្ណៈ ៖ ចៅហ្វាយស្រុកមានតាមោង តាសំអាត!

គីមរស់ ៖ តាមោង តាសំអាត ។

វណ្ណៈ ៖ ហើតាឆាង ខាងសេដ្ឋកិច្ច ។

គីមរស់ ៖ ចា៎!

វណ្ណៈ ៖ តាវាល់ អគ្គមេបញ្ជាការប្រព័ន្ធទំនប់ប្រឡាយតំបន់៥?

គីមរស់ ៖ ចា៎! ហ្នឹងឯង ។

វណ្ណៈ ៖ កាលអ្នកទាំងអស់ហ្នឹងមក ដូចថាយាយ ចែម អីមិនទាន់មកទេ?

គីមរស់ ៖ អត់ទាន់មកទេ! យាយចែមមិនទាន់មកទេ យាយ ចែម មកក្រោយ ។

វណ្ណៈ ៖ ដូចថាអ្នកទាំងអស់ហ្នឹងគ្រប់គ្រងដូចថាមានសម្លាប់មនុស្សមានអីនៅ តាវាល់ តាអីហ្នឹង?

គីមរស់ ៖ មានសម្លាប់ដែរ ប៉ុន្តែតិចតួច ។

វណ្ណៈ សម្លាប់ដូចតែគ្នាហ្នឹង ។

គីមរស់ ៖ ទេ! កាលនោះមិនទាន់សម្លាប់ប៉ុន្មានទេ វាមិនសូចខ្លាំងខ្លា វាមិនសូវចងទាំងខ្សែៗណាកាលខ្ញុំនៅហ្នឹង ដូចថាទាហានអីសម្លាប់ហើយណា ដល់ពួកចល័តអីទៅមិនឃើញទេ ខ្ញុំឃើញសម្លាប់តែអានួយទាហាន ។

វណ្ណៈ ៖ អីចឹងតាមោង តាសំអាតអីស្លាប់ហើយ គេចាប់ខ្លួនគាត់?

គីមរស់ ៖ បាត់អស់ហើយ ពួកនិរតីមកគេចាប់យកទៅវៃចោលខ្ទេកៗអស់ហើយ ដូចសំរោចដូចអី ។

វណ្ណៈ ៖ តាសំអាតគេចាប់ដែរ?

គីមរស់ ៖ ចាប់អស់គ្មានសល់អាណាមួយទេ ។

វណ្ណៈ ៖ ចុះតាឆាង!

គីមរស់ ៖ ឆាប់អស់ហើយ គ្មានសល់ណាមួយទេ ។

វណ្ណៈ ៖ តាវាល់?

គឹមរស់ ៖ ផាប់អស់ និរតីមកចាប់វៃចោលអត់សគ្មានសល់ទេ ។

វណ្ណៈ ៖ តាហ៊ឹង?

គឹមរស់ ៖ មុនគេ យូណាស់! តាញ៉ឹម តាជាល តាអីវៃអស់ និរតីវៃចោលអស់គ្មានសល់អីមួយ គ្មានអ្នកណានៅមួយទេ ផាប់អស់រលីង ។

វណ្ណៈ ៖ ចុះមានដឹងថាតាមោង តាសំអាត គេចាប់ឆ្នាំណាមីងដឹងទេ?

គឹមរស់ ៖ ចាប់ឆ្នាំ៧៨ ហ្នុងឯង អូ៧៧ មិនដឹង ឆ្នាំ៧៧ ខែវស្សាអីចេះឯង លើកទំនប់ឯណុះ លើកទំនប់នៅរន្ទះបាញ់នោះណា ។

វណ្ណៈ ៖ ដូចគ្នាតាអាតអីហ្នឹង?

គឹមរស់ ៖ ចា៎!

វណ្ណៈ ៖ ចុះតាហ៊ីងគេចាប់មុន?

គឹមរស់ ៖ ចា៎! ចាប់ក្នុងឆ្នាំជាមួយគ្នាហ្នុងឯង ប៉ុនគ្រាន់ថាមុនបណ្ដើរៗណា រយៈពេលវាបន្តៗ ចាប់ពីលើមក ចាប់ពីលើមកមុន តាញ៉ឹម មក បានមកតាហ៊ីង បន្តៗ ពីលើគេស្រាវក្រោម បន្តៗមកបានអស់ ស្រុក ភូមិអីអស់រលីញ ស្រុកក៏អស់ភូមិក៏អស់បោសរលីញ ។

វណ្ណៈ ៖ ចុះតាក្រក់អីក៏សល់ដែរ?

គឹមរស់ ៖ តាក្រក់ហ្នុងក៏គេយកទៅវៃចោល តាសន អាអី ។

វណ្ណៈ ៖ អីចឹងមីងខ្ញុំចង់បកទៅសួរកាលមីងនៅធ្វើទំនប់វិញ! ៧៧ មីងទៅហើយណា?

គឹមរស់ ៖ ចា៎!

វណ្ណៈ ៖ ទៅធ្វើទំនប់អាងត្រពាំងថ្ម?

គឹមរស់ ៖ ចា៎! ទៅលើកទំនប់អាងត្រពាំងថ្ម ខ្ញុំកាន់ខ្សែត្រៀមស្ពានទី៣ ហ្នឹងស្ពានរាប ចំកណ្ដាលស្ពានរាប ។

វណ្ណៈ ៖ ខ្ញុំចង់ឲ្យមីងរៀបរាបកាលមីងទៅធ្វើទំនប់ហ្នុង មីងឃើញព្រឹត្តិការយ៉ាងម៉េចខ្លះដែរ ជួបការលំបាកយ៉ាងម៉េច?

គឹមរស់ ៖ គេឲ្យលើកមួយថ្ងៃ៣ម៉ែត្រគីប ។ បាយគេឲ្យរបបឃើងមួយចានចង្កឹះ ម្ហូបអត់មានអីទេ មានតែទឹកប្រហុក បានតែម្ហូបទឹកប្រហុកហ្នុងឯង ។

វណ្ណៈ ៖ ប៉ុនឲ្យបាយដែរន៎?

គឹមរស់ ៖ ចា៎! បាយមួយចានចង្កឹះ ម្ហូបទឹកប្រហុកហ្នុងឯង អត់មានម្ហូបឆ្ងាញ់ទេ ។

វណ្ណៈ ៖ ចុះបើ ៣ម៉ែត្រគីបហ្នឹងអត់ហើយ?

គីមរស់ ៖ ៣ ម៉ែត្រគីបមិនហើយ ទេប៉ុននោះដូចមិនធ្វើអីធ្ងន់ធ្ងរអីប៉ុន្មានទេ បើមិនហើយឲ្យធ្វើទាល់តែហើយ ថែមយប់ឡើងឲ្យហើយ ។

វណ្ណៈ ៖ យប់យើងទៅធ្វើទៀតទៅ?

គីមរស់ ៖ ចាំ!

វណ្ណៈ ៖ ស្អែកវាស់ថ្មីទៀត?

គីមរស់ ៖ ចាំស្អែកវាស់ថ្មីទៀត ឲ្យធ្វើទាល់តែហើយ បើសិនជាអ្នកណាមិនហើយ ទុកសិនទៅ យប់ឡើងទៅបង្ហើយឲ្យហើយ ស្អែកឡើងបានធ្វើទៀត ។

វណ្ណៈ ៖ ចុះកន្លែងដេកយ៉ាងម៉េចដែរមីងកន្លែងដេក?

គីមរស់ ៖ កន្លែងដេកគគ្រិច ។

វណ្ណៈ ៖ រោង?

គីមរស់ ៖ រោងវែង ។

វណ្ណៈ ៖ មានគ្រែ មានអីទេ?

គីមរស់ ៖ ទេ! មានតែរោងដេកនៅនឹងដីហ្នឹង ក្រាលការ៉ុង ក្រាលអីយើងដេកទៅ ភួយក្រណាត់ យើងយកទៅ ពីពីង ដោយសាររឿងៗខ្លួន ចបបង្គីរដេកកើយ កាលណាចប់មុត បង្គីរល្អ យើងរែករួចបង្ហើយដែនការ កាលណាចប់បង្គីរមិនមុតគេលួចអស់ ចបមុតអីគេលួចអស់ បើយើងទុកមិនល្អ ។

វណ្ណៈ ៖ មានលួចដែរ?

គីមរស់ ៖ ចាំ! លួចគ្នា លួចបង្គីរលួចចប ដើម្បីយកទៅធ្វើឲ្យហើយដែនការ ។

វណ្ណៈ ៖ លួចដូរទេ មិនមែនលួចបាត់ម៉ង?

គីមរស់ ៖ លួចបាត់ម៉ង លួចយកទៅធ្វើបាត់ទៅណា ។

វណ្ណៈ ៖ អ្នកដែលបាត់អង្គការមិនរករឿង?

គីមរស់ ៖ អ្នកណារកមិនឃើញ រកអាកញ្ចេះកញ្ចាស់យកទៅធ្វើទៅ អានេះបានថាហើយទុកដាក់មិនម្ចាស់ការ មិនល្អ អីចឹងហើយម្នាក់ៗសុទ្ធតែចងចំណាំរៀងៗខ្លួន ដេកឱបដេកកើយ ទុកឲ្យល្អ ស្គាល់ឧបករណ៍រៀងៗខ្លួនៗ គ្មានអ្នកណាទៅលួចអ្នកណាបានទេ មុនដំបូងលួចគ្នាវល់វិទៅ ដល់តែនេះទៅប្រាប់ទៅប្រធានគេទៅ ឲ្យម្ចាស់ការទទួលខុសត្រូវរៀងខ្លួន ខ្លាចអ្នកលួចរបស់អ្នកណាទៅឲ្យមានចំណាំ មានអីទៅ គេហ្នឹងរកខុសត្រូវឲ្យ ហើយកាលលើកទំនប់នេះខ្ញុំចប់អាខ្សែត្រៀមនេះទៅ បានខ្ញុំបញ្ជូនទៅកូនខែ្វងទៅបានគេឲ្យមកមើលសិល្បៈ

នោម ឆវិន នេះឯង ក្រោយពីលើកនៅកូនខ្វែងហើយ បានវេទនាខ្លាំង វេទនាណាស់ ឆ្ងាយទឹក អត់មានទឹកផឹក ហើយខែក្ដៅផង ខែចែត្រនោះ យើងលើកក្រោយ ចែត្ររួចនោះ ក្ដៅក៏ក្ដៅ ទឹកក៏គ្មាន ទឹកបានក្នុងមួយកងធំបានម៉ាកន្ដាំង៣០ ហ្ហូ!ក្នុងមួយវរៈគ្នា ៣០០នាក់បានមួយកន្ដាំងធំ ៣០លីត្រ ព្រោះទឹកគេដឹកទៅឲ្យនោះ គេដឹកទៅឲ្យ គេចែកតាមវរៈ ក្នុង៣០០នាក់បាន៣០លីត្រ ហើយ ៣០លីត្រយកមកចែកគ្នាទៀតទៅ ចែកគ្នាក្នុងមួយក្រុមបានមួយកំប៉ុង... ផឹកតែម្នាក់អស់ហើយ ព្រោះស្រេកខ្លាំងណាស់ មានធ្វើអី វាល់ចែកគ្នា វាល់ហ្នឹងស្លាបព្រាចែកគ្នា ។

វណ្ណៈ : ទឹកហ្នឹង?

គីមរស់ : ចា៎! ទឹកផឹកហ្នឹង ដាច់ទឹកថាវាអត់ដល់ថ្នាក់ប៉ុណ្ណឹងណា ចុះឡានវាតែមួយ ហឺដោះស្រាយមនុស្សរាប់ពាន់អ្នកណា ដោះស្រាយមិនទាន់ ដឹកមកមិនទាន់ណា គ្រាន់តែបានមកដោះអស់មួយភ្លែត ដល់អីចឹងទៅអ្នកណាបានមួយកំប៉ុងផឹកតែឯង សើច.. វាល់ចែកគ្នា រួចទៅបាយ គេឲ្យបាយ ឲ្យម្ហូប ប៉ុន្តែយើងអត់មានទឹកលាងទេ បាយញាំហើយ គឺថាយើងបោសៗចាន ប្រកសកាដូទុកវិញទៅ ។

វណ្ណៈ : អីចឹងចែកចានមួយម្នាក់?

គីមរស់ : ចា៎! ចានយើងមានរៀងខ្លួន យើងយកពីនេះមកដាក់សកាដូទៅរៀងខ្លួន ។

វណ្ណៈ : អីចឹងនៅកន្លែងហ្នុងគេមានរោងបាយ រោងអីចឹងដែរ?

គីមរស់ : ចា៎! មានអ្នកដាំបាយ គេធ្វើអ្នកដាំបាយ ដាំអីឲ្យយើងហូបដែរ ។

វណ្ណៈ : បើតាមនិយាយទៅមនុស្សបែបនៅហ្នុងប្រហែលជាច្រើន ផងិតទំនប់ម៉ងតាមមើល?

គីមរស់ : ចា៎! មនុស្សឡើងខ្មៅរោល ។

វណ្ណៈ : រាប់ម៉ឺននាក់?

គីមរស់ : រាប់ម៉ឺននាក់ សួរថាចាប់ផ្ដើមខ្សែត្រៀមយើងវាល់ទៅណា យើងវាស់បន្ដគ្នាអីចេះណា មកដូចនេះខ្ញុំ ខ្ញុំនៅអីចេះណា នេះ២ម៉ែត្រ មក២ម៉ែត្រៗមករៀងគ្នារហូតមុខយើង យើងរែកចាក់មក ប៉ុន្តែដីយើងចេះតែកាប់រុញមកមុខរហូត ៣មែត្រក្នុងមួយថ្ងៃ មុនដំបូងគេឲ្យចុះអន្ទង មួយថ្ងៃតែ២ម៉ែត្រទេ អាយើងកាប់ចុះក្រោមដំបូងណា ដល់ថ្ងៃក្រោយបានគេវាល់ឡើង៣ម៉ែត្រ យើងចេះតែដេញមកមុខទៅ យើងចេះតែដេញមក យើងរែកឡើងចាក់ទាល់តែពេញហ្នុងទៅ ទាល់តែពេញទំនប់ទៅ មនុស្សទៅដាក់គរឡើងមីដេដាស អីចុះហើយមើលទៅសុទ្ធតែមនុស្សលើងខ្មៅរោល ។

វណ្ណៈ : គេចែកគ្នាជាក្រុមៗ ជាកងរយ?

គឹមរស់ : ចាំ! ជាក្រុម ជាកងរយ ។

វណ្ណៈ : កងមីងប្រហែលប៉ុន្មាននាក់ទៅ?

គឹមរស់ : កងខ្ញុំមួយរយនាក់ ទេទៅពីនេះទៅច្រើន ៣០០នាក់ ប៉ុន្តែទៅបណ្តើរៗ ខ្ញុំក៏នៅគេចែកតាមក្រុម តាមកង ក៏នៅក្នុង២០, ៣០ នាក់នោះណា ដល់លើកទៅវែងគ្នាទៅ នៅកូនខ្វែងបាន មានគេចាប់យកទៅវៃចោល ចាប់អានួយ ចាប់អីហ្នឹង ទាហាន ។

វណ្ណៈ : អីចឹងខ្ញុំសួរលំអិតរឿងអាងត្រពាំងថ្មសិនណាមីងណា អាងត្រពាំងថ្មហ្នឹងមីងឃើញថ្នាក់ដឹកនាំណាខ្លះដែលខស្សហ៍ទៅកន្លែងហ្នឹងម៉ង មានពីណាខ្លះ?

គឹមរស់ : ដឹកនាំទៅពីណាទេ ឃើញតែចុះជាប់ពីនេះទៅគេដាក់ទៅ ក៏គេចែកតាមកង វែកទៅមានពីណាទេ ។

វណ្ណៈ : អ្នកធំអី ដូចជាថ្នាក់ស្រុក ថ្នាក់តំបន់អី គេទៅ ដែលទៅមើលទេមីង?

គឹមរស់ : អ្នកធំថ្នាក់ស្រុកថ្នាក់តំបន់ មានតែតាវ៉ាល់ហ្នឹងហើយ គាត់ទៅ គាត់នៅក្តាប់នៅហ្នុងតាវ៉ាល់ ប៉ុនយើងនេះគេបែងចែកទៅតាមស្រុក ស្រុកគេបញ្ជូនទៅ ថាមានអ្នកតាមពីស្រុកហ្នឹងទៅ ។

វណ្ណៈ : ទំនប់ហ្នុងទទឹងវាប្រវែងប៉ុន្មាន ហីកំពស់វាប្រហែលប៉ុន្មាន?

គឹមរស់ : កំពស់ប្រហែល៧ម៉ែត្រកាលលើកកាលណុះណា ក្បាលវា៥ម៉ែត្រ ។

វណ្ណៈ : គេថាជៀសឡាន២រួចអីនោះ?

គឹមរស់ : ចាំ! ៥ម៉ែត្រ ហីដើងទេវាប្រហែលជាប៉ុន្មានដែរទេ ដូចថាយើងក្តាប់វាមិនបាន គេថាអើវែកចេះតែវែកទៅណា ។

វណ្ណៈ : បាទ! ប៉ុន្តែអាងហ្នុងធំទំ?

គឹមរស់ : ចាំ! អាងហ្នុងធំណាស់ អាត្រពាំងថ្មមានដែលទៅទេ?

វណ្ណៈ : ទៅម្តងតែ ប៉ុន្តែមិនបានទៅជុំវិញទាំងអស់ ។

គឹមរស់ : អូ! ធំណាស់ ។ អាង ហ្នុងធំជាងបារាយ៍ទៀតណំ ។

វណ្ណៈ : ប៉ុន្តែកាលខ្ញុំទៅសំបូរទឹក ប៉ុន្តែកាលមីងទៅលើកហេតុបានជាអត់មានទឹក?

គឹមរស់ : គ្មានទឹកទេ! ដីស្រែធម្មតាហ្នុង ហើយព្រៃឈើហ្នឹង ដល់យើងលើកទំនប់នោះទប់បានទៅបានទឹកនោះវានៅ កាលមុនជាដីធម្មតាតើស ។

វណ្ណៈ : ខ្ញុំគិតថាទៅលើកអាងៗមិនគួរណាទៅខ្វះទឹកទេ ខ្ញុំគិតអីចឹងណា?

គីមរស់ ៖ ចា៎!

វណ្ណៈ ៖ ដល់ខ្ញុំជួបសម្ភាសន៍ទៅថាអត់មានទឹកទេ មនុស្សកើតចៃទៀត?

គីមរស់ ៖ ចា៎! ហីខ្ញុំអាពេលនោះ ២១ ថ្ងៃ អត់ទឹកណា មើលខ្ញុំនិយាយរៀបរាប់ដល់កន្ទែងទឹកអត់មានទឹកដឹក បាយយើងញាំ សាកាជូប្រកដែរណា អាហ្នុងអត់មានទឹកដឹក សូម្បីតែងូត ក៏មិនបានងូតដែរ ២១ ថ្ងៃត្រឹម ហីខ្ញុំនិយាយពីស្គម ស្គមឡើងខ្មៅក្រញេះ ស្គមសុទ្ធតែឆ្អឹងនោះណា និយាយពីចេញចៃ អាវនេះចេញចៃហើយ អាវយើង អាអាវកខុបអីចេះណា ដោះមកក៏ចៃតាមកអាវ តាមថ្នេរអាវ សុទ្ធតែចៃ ចេញ អាហ្នុងនៅខ្សែត្រៀមកូនខ្វែង ។

វណ្ណៈ ៖ កូនខ្វែងហ្នុងត្រពាំងថ្មដែរ?

គីមរស់ ៖ ចា៎! ទៅដើង មុនដំបូងយើងលើកនៅស្ពានរាបនេះ ដល់នេះគេទៅនៅខ្សែត្រៀមកូនខ្វែងទៅពង្រ បណ្តើរទៅអីចេះ បណ្តើរទៅពង្រហើយបានទៅកូនខ្វែងណុះ នៅលើកស្ពានទីពចប់ស្ពានទីពទៅជាប់ខ្សែត្រៀមពង្រទៅបានទៅកូនខ្វែង ។

វណ្ណៈ ៖ ចុះមីងនៅកងមីងមានបាត់មនុស្សបាត់អីខ្លះៗទៀតទេ ឬក៏អត់ទេ?

គីមរស់ ៖ ទេ! ខ្ញុំអត់មានបាត់ទេ ។

វណ្ណៈ ៖ តែមីងមានដឹងអ្នក១៧មេសាអីនៅហ្នឹង ដូចថាធ្វើការមិនសូវស្វាហាប់អី គេសម្លាប់ គេចាប់យកទៅសម្លាប់ទេ?

គីមរស់ ៖ ចាប់តែទាហាន គេជ្រើសរើសប្រវត្តិណា អាហ្នឹងស្រាវជ្រាវប្រវត្តិអីទេ ។

វណ្ណៈ ៖ ចុះពួគេថាអ្នកតែស្លាប់គេកប់នៅអាងត្រពាំងថ្ម នៅដើងទំនប់ហ្នុងមែនដែរឬទេ?

គីមរស់ ៖ ខ្ញុំដូចជាមិនឃើញមាន យើងលើកដីដាក់ ។

វណ្ណៈ ៖ ប៉ុន្តែដឹងថានៅអាងត្រពាំងថ្មហ្នុងក៏មានមនុស្សស្លាប់ដែរ?

គីមរស់ ៖ ចា៎ៗ! មានមនុស្សស្លាប់រាប់រយ រាប់ពាន់នាក់ដែរ ស្លាប់ដោយឈឺ ស្លាប់ដោយអីៗ ស្លាប់ដោយគេវៃចោលអីនោះឯង ប៉ុន្តែមិនសូវខ្លាំងដូចអាកាល៧៨ មានស្លាប់ដែរ ។

វណ្ណៈ ៖ ដល់ពួកនិរតីចូលមកគេទៅចាប់ពួកតាវ៉ាល់ សម្លាប់ទៅពួកណាគេគ្រប់គ្រងវិញ?

គីមរស់ ៖ ចា៎! ពួកនិរតី យាយ ចែម ចៅហ្វាយស្រុក យាយ ចែម សាហាវហើយ ខ្លាំងហើយ ។

វណ្ណៈ ៖ អីចឹងដល់ពេលយាយចែមមកមនុស្សកាន់តែស្លាប់ច្រើនទៅ?

គីមរស់ ៖ យាយ ចែម មកពួក និរតីទាំងអស់ ពួកនោះឯងដែលសម្លាប់ចោលអស់រាប់គំនរ សម្លាប់ចោលមែនទែន ពួកនោះហើយ ចាប់យកៗ ចងទាំងខ្សែៗ ទៅវៃចោលនៅដើងភ្នំ

ក្រោយផ្ទះតាក្រក់នោះ អន្ទង់ ប៉ុនៗស្រះនោះ ទេពួកមុនមិនសូវវៃប៉ុន្មានទេ ពួកមុនវៃដែរ ប៉ុន្តែរកតែទាហានរកតែស្អីៗណា ។

វណ្ណៈ : បន្ទាប់ពីយាយចែមស្គាល់ទេ ក្រោពីយាយចែមមក?

គឹមរស់ : បន្ទាប់ពីយាយចែមមក ប្រធានឃុំនោះឈ្មោះ បង ថា ។

វណ្ណៈ : គណៈឃុំឈ្មោះ ថា?

គឹមរស់ : ថា ។

វណ្ណៈ : គណៈឃុំនៅឯណាហ្នុង?

គឹមរស់ : ព្រះនេត្រព្រះ ថា ហើយ តាខុន តាអីទេ ។

វណ្ណៈ : អីចឹងអ្នកដែលជិះទូសកន្ទែងតាវ៉ាល់ តាអីហ្នឹង?

គឹមរស់ : តាពាល់ ជិះទូសតាវ៉ាល់ហ្នុង តាពាល់ ។

វណ្ណៈ : តាពាល់ហ្នឹង គាត់គណៈតំបន់ ឬគាត់ចៅហ្វាយស្រុក?

គឹមរស់ : គណៈតំបន់មិនដឹង ទេគាត់មិនមែនគណៈតំបន់ទេ តាពាល់គាត់គណៈ ដូចតាវ៉ាល់អីចឹងណា ជិះទូសកន្ទែងតាវ៉ាល់ គណៈតំបន់នេះ អ្នកណាអីចេះនិរតីនោះ មិនស្គាល់ទេ ។

វណ្ណៈ : ដល់ក្រោយៗមកហ្នឹង ដូចជារាងច្របូកច្របល់បន្តិច ពេលចាប់តាវ៉ាល់ តាអីហ្នុង?

គឹមរស់ : ចា៎! ចាប់តាវ៉ាល់ តាអីហ្នុងចោលទៅ ខ្ញុំក៏មកសំងំរស់ ខ្ញុំទៅចល័តមួយសា មួយលើកទៀត ៧៨មួយលើកទៀត លើកនៅឯណុះ លើកនៅភូមិរូង លើកនៅស្ពានស្រែងបើ៧៧ លើកនៅនេះ ផ្លូវទៅស្រះលិចនេះ ៧៧ដែរ អានេះលើក៧៧ ហើយតាម៉ោងតាអីនៅ ដល់ខ្ញុំលើកអានេះចប់ទៅបានទៅស្ពានរន្ទះបាញ់ណុះ លើកអាស្ពានរន្ទះបាញ់រួចបាន ផ្អើលថាគេចាប់ពួកតាមោង តាអី តាវ៉ាល់តាអីវៃចោលអស់នេះមួយសារទៅបានឡើងពីនោះមកវិញ ពួកនិរតីមក ក៏មកនៅក្នុងភូមិនៅជាមួយនិរតីទៅ នៅជាមួយនិរតីមួយសន្ទុះ បានខែប្រាំងគេបញ្ជូនទៅទៀត គេបញ្ជូនទៅឲ្យលើកទំនប់ទៀត ទៅលើកខាងណុះ លើកខាងស្ពានស្រែងម្តង ទៅខាងកើតភ្នំស្រុក ខាងស្ពានស្រែងអីលើកអានេះលើកទំនប់តាមផ្លូវទៅសៀមរាបនេះ លើកអាអូលៀសនេះ ហ្នឹងពួកនិរតីមកហើយប្រធានខ្ញុំបងស៊ា បងយននេះ ។

វណ្ណៈ : ប្រធានកងចល័តនៅត្រពាំងថ្មហ្នុងពីណាគេ?

គឹមរស់ ៖ បងបឿន បងឆន អា៧៧ បងបឿន បងឆន។ បងបឿន ដូចទៅណា បងឆន ដូចជានៅមិនដឹង ឬស្លាប់អស់ហើយមិនដឹង មិនដឹងទៅណាទេ ខ្ញុំនៅណោះបែកគ្នារហូត មិនដែលឃើញគ្នា មិនដឹងគេយកទៅវៃចោល ឬនៅ។

វណ្ណៈ ៖ អ៊ីចឹងយាយថែមអ៊ីចឹង អាពេលចាប់កងចល័តហ្នុង មានពីណាខ្លះនៅមើលកងចល័តហ្នុងយាយថែមអីគាត់ទៅទេ?

គឹមរស់ ៖ យាយថែម គាត់ចៅហ្វាយស្រុក។

វណ្ណៈ ៖ គាត់ចុះទៅទេ! គាត់ចុះទៅមើលកន្លែងទំនប់ហ្នឹងទេ?

គឹមរស់ ៖ ទេ! គាពាល់តើស! គាពាល់គាត់ចុះមើល យាយថែមមិនបាននៅមើលទេ គាពាលទេចុះមើលទំនប់។ ខ្ញុំ មេកងខ្ញុំ បងយន និងបងទាវ ស្រីៗ សុទ្ធតែស្រីៗទេ ព្រោះក្តាប់ផ្ទាល់មិនសូវមានប្រុសទេ សុទ្ធតែស្រីៗនិរតីមកណា តែបងយន បងទាវទេ ដែលនៅក្តាប់ខ្ញុំ។

វណ្ណៈ ៖ អ៊ីចឹងយាយថែម គាត់អត់សូវបន្ទាញមុខទេន៎?

គឹមរស់ ៖ ទេ! យាយថែមគាត់ចៅហ្វាយស្រុកនោះ បន្ទាញដែល មានអីមិនបន្ទាញគាត់។

វណ្ណៈ ៖ មីងកាលហ្នឹងមានធ្លាប់ឃើញគាត់ទេ?

គឹមរស់ ៖ អូ! មែនកាលគេវៃអាអ្នកខុសសីលធម៌នោះ កាលគេវៃនោះនិរតីមកហើយ។

វណ្ណៈ ៖ ពីណាគេខុសសីលធម៌?

គឹមរស់ ៖ ខុសសីលធម៌ឈ្មោះមីភេត និងស្អីទេ ភ្លេចបាត់ទៅហើយ ខុសសីលធម៌ប្រុសមួយ ស្រីមួយហ្នឹងឯង។

វណ្ណៈ ៖ វៃចោលឆ្នាំណាអ្នកដែលខុសសីលធម៌?

គឹមរស់ ៖ ឆ្នាំ៧៧ ហ្នឹងឯង ខែវស្សាប្រហែលជា ខែ៩ ខែ១០អីហ្នឹងឯង។

វណ្ណៈ ៖ គេយកវៃដែរ?

គឹមរស់ ៖ វៃចោលនៅវត្តនេះ តាមផ្លូវបំបែកយើងសព្វថ្ងៃនេះណា នេះអាកាច់ជ្រុងយើងចូលមកណោះ អាមួយចុះមកផ្សារ អាមួយចុះមកត្រង់ណោះ វៃត្រង់ហ្នឹងឯង កាច់ជ្រុងវត្តនោះ ...គេវៃចោលនោះហើយទៅកងចល័តរហូត ខែ ៨ ខែ ៩ នេះឯងវៃខ្លាំងជាងគេ ខែភ្ជុំបុណ្ណនេះឯង ខែ៨ ខែ៩ ខែណោះនេះគេចាប់ផ្តើមហើយ ប៉ុនអាវៃខ្លាំងពេញជីនរយៈពេលតែមួយខែ ពីរខែទេ ខែ៨ ខែ៩ ហ្នឹងឯង វៃខ្លាំង ភ្លៀងស្រិចៗគេចង់ទាំងខ្សែណាទៅវៃចោល។

វណ្ណៈ : ខែ ៨ ខែ ៩ ឆ្នាំណា?

គឹមរស់ : ៧៨ ពួកនិរតីចាប់វៃចោលនៅភូមិ បើភូមិបុស្តិ៍ចាស់នេះ ខ្ញុំភូមិប្រោយសំរោងនេះ គេនៅបុ័ស្តិ៍ចាស់ ។

វណ្ណៈ : អីចឹងពួកនិរតីមកមិនថាអ្នកថ្មី មិនថាអ្នកចាស់វៃចោល?

គឹមរស់ : មិនថាអ្នកថ្មី មិនថាអ្នកចាស់ទេវៃចោល វៃចោលទាំងអស់ មិនថាអ្នកថ្មី មិនថាអ្នកចាស់ទេ អាអ្នកចាស់ក៏ងាប់ អ្នកថ្មីក៏ងាប់ ។

វណ្ណៈ : អីចឹងពួកនិរតីមកមិនថាអ្នកថ្មី មិនថាអ្នកមូលដ្ឋានទេវៃចោលទាំងអស់?

គឹមរស់ : វៃចោលទាំងអស់ មិនថាអ្នកថ្មីមិនថាអ្នកចាស់ទេ អាអ្នកចាស់ក៏ងាប់ អាអ្នកថ្មីក៏ងាប់ ចងវៃចោលទាំងខ្សែៗនោះឯង អាផ្នកចាស់ក៏ចាប់អាអ្នកថ្មីក៏ចាប់ ងាប់ឡើងអស់ ទាំងខ្សែ គេយកទៅវៃចោល ពួកនិរតីនោះឯង ឈ្មោះវា បងសាត មីកាហឿន បងសាត និងបងហឿន ហ្នឹងឯងអ្នកវៃខ្ញាំងជាងគេ បងរុន, សាត, ហឿន។ ហឿន នេះវៃខ្លាំង ជាងគេ អូ! សាត ការុន កាហឿន គ្នាវាហ្នុង ។

វណ្ណៈ : ពីណាបងសាត បងហឿន...

គឹមរស់ : សាត, កាហឿន, ការុន, ខុន ។

វណ្ណៈ : ខុន ហ្នុងស្រី ឬប្រុស?

គឹមរស់ : ស្រីទាំងអស់ ។

វណ្ណៈ : ស្រីទាំងអស់!

គឹមរស់ : សុទ្ធតែស្រី សុទ្ធតែនារីនិរតីទាំងអស់ ។

វណ្ណៈ : អ្នកហ្នឹងជនដៃដល់?

គឹមរស់ : ចា៎! នារីនិរតីទាំងអស់ ។

វណ្ណៈ : ហ៊ានវៃ ហ៊ានអី...

គឹមរស់ : អូ! សុទ្ធតែវាចាប់ចងយកទៅទាំងខ្សែៗ យកទៅវៃហើយ ពួកវាសុទ្ធតែលាត់ជើងខោវៃ រត់ខ្វាយដូចក្នុងវីដេអូអីចេះឯង ពួកវានេះ ។

វណ្ណៈ : អីចឹងពួកហ្នឹងហ៊ានដល់អ្នកសម្លាប់ទៀតអីចឹង?

គឹមរស់ : ចា៎! ពួកនេះសុទ្ធតែវៃផ្ទាល់ហើយ ។

វណ្ណៈ : ឈ្មោះ សាត ឈ្មោះ ហឿន ឈ្មោះ រុន ឈ្មោះ ខុន!

គឹមរស់ : ចា៎! អូឈ្មោះឯងសម្ភាសន៍អីចេះ ពួកវាពុឈ្មោះឯងទីឯងទៀតហើយ ។

វណ្ណៈ : អត់អីទេ អត់មានចាក់តាមវិទ្យុទេ យើងគ្រាន់តែស្រាវជ្រាវទុកជាឯកសារប្រវត្តិសាស្ត្រ ក្មេងអាចបាន រៀនថ្ងៃក្រោយគេដកស្រង់ទៅ គេបង្រៀនតាមសាលា ដូចថាយើងម៉ាសន្តមៗ យើងត្រូវតែមាន យើងឆ្លងផុតទៅ យើងទៅមុនបាត់ទៅ សល់ក្មេងៗក្រោយដឹងថាប្រវត្តិស្រុកខ្មែរយើងជួបបញ្ហាអីខ្លះកើតឡើងក្នុងសម័យមុនៗអីចឹងទៅ ។

គឹមរស់ : ចាំ!

វណ្ណៈ : នេះយើងអត់យកទៅផ្សាយផ្ទាល់តាមវិទ្យុតាមអីទេ គ្រាន់តែយើងកត់ច្រើនទេបាទ ។

គឹមរស់ : កុំយកទៅផ្សាយទៅអី កុំឲ្យពិបាកវាឃើញវាអី វានៅខ្លះពួកហ្នុង មិនងាប់ទេ ពួលវានៅ ។

វណ្ណៈ : អាចរត់៧៩ អាចទៅនៅជាយដែនពួកហ្នឹងណា?

គឹមរស់ : វានៅជាយដែននៅអីនោះ មីកាហឿន វាមកថ្ងៃណុះជួបគ្នាតើសមីកាហឿន (សើច) ។

វណ្ណៈ : ហឿន ហ្នុងនៅរស់ឬ?

គឹមរស់ : នៅរស់តើស! មកថ្ងៃណុះឯង ។

វណ្ណៈ : តែអត់ដឹងថាគាត់នៅឯណាទេណ៎?

គឹមរស់ : កាហឿននៅឯណាទេ នៅប៉ៃលិន នៅជាមួយតាអ៊ី ឈាន ហ្នុង កូនចៅតា ឈាន នោះឯង ឲ្យតែនិយាយ និយាយចុះនិយាយឡើងមកវិលនៅតែដដែលហ្នុងហើយ ខ្ញុំមិនចង់និយាយផង ។

វណ្ណៈ : បាទ! អានេះគ្រាន់តែយើងជាប្រវត្តិសាស្ត្រ យើងមិនអាចទៅសងសឹកសងអីទៀតទេ!

គឹមរស់ : មិនសងសឹកសងអីទេ គ្រាន់ថា...

វណ្ណៈ : ឥឡូវនេះយើងគ្រាន់តែឲ្យមានការកាត់ទោសទៅដើម្បីឲ្យដឹងសខ្មៅ ហើយក៏យើងមិនមានចងកម្មពារអីទៀតដែរ អីចឹងឈ្មោះ សាត អីដឹងនៅដែរអត់ ឈ្មោះ សាត?

គឹមរស់ : បងសាត មិនដឹងនៅអត់ទេ បើមីហឿន ដឹងថានៅ វាជួបខ្ញុំ ។

វណ្ណៈ : ចុះរុន ផុន អី?

គឹមរស់ : រុន, ផុន អី..

វណ្ណៈ : សាត អី មានដឹងថាគាត់នៅឯណាទេ?

គឹមរស់ : នៅតាកែវ ពួកតាកែវទាំងអស់ មកពីតាកែវ សុទ្ធតែពួកមកពីតាកែវហើយ ។

វណ្ណៈ : អីចឹងដល់ពេលក្មេងស្រីៗទេណ៎ សាហាវជាងបុរសៗទៀត?

គឹមរស់ : អូ! សុទ្ធតែស្រីៗទេ វ៉ៃនោះមិនមែនប្រុសទេ ស្រីៗ អីវាចាប់វាចង យប់ឡើងវាចាប់ចងទាំងខ្សែៗ វ៉ៃចោលនៅហ្នុងនោះ ។

វណ្ណៈ : មុននឹងវ៉ៃចោល គេមានគុកសន្តិសុខគេនៅឯណាទេ មីងដឹងទេ?

គីមរស់ : នៅកន្លែងតាក្រក់ហ្នុង ពីដើមមិញគណៈឃុំគេនៅត្រង់ណុះឯង កន្លែងនេះណា អាកន្លែងខ្លោងទ្វាចូលភ្នំអរិយកម្ម អាកន្លែងគេដាក់លក់គ្រឿងសំណង់ទៅមានផ្លូវគេចូលត្រង់នេះ ។

វណ្ណៈ : កន្លែងហ្នុងមានដាក់ឃុំមនុស្សដែរ?

គីមរស់ : អាខាងជើងនេះឯង អាកាចជ្រុង ខាងត្បូងនោះមិនមាន ផ្លូវមកអីចេះមិនមាន ផ្លូវនេះមកជប់ អានេះមិនផ្លូវមកភ្នំ នេះម្ដុំត្រង់ណេះឯង តាក្រក់គាត់នៅម្ដុំឃុំ នៅត្រង់ណុះឯង ។

វណ្ណៈ : ឃុំព្រះនេត្រព្រះហ្នឹងប្ត?

គីមរស់ : ចា៎! ឃុំព្រះនេត្រព្រះហ្នុង ត្រង់ផ្ទះតាក្រក់ហ្នុង ។

វណ្ណៈ : កន្លែងហ្នុងសម្លាប់មនុស្សដែរ?

គីមរស់ : ចា៎! ខាងក្រោយហ្នុងហើយ សម្លាប់ខាងក្រោយផ្ទះតាក្រក់ហ្នុងឯង ខាងក្រោយមកជើងភ្នំនេះឯង ។

វណ្ណៈ : អីចឹងពួកនិរតីមក មកនៅទីតាំងតាក្រក់ដែរ?

គីមរស់ : ចា៎! មកនៅដែរ ។

វណ្ណៈ : មករស់នៅហ្នឹងដែរ?

គីមរស់ : ចា៎! នៅហ្នឹងដែរ នៅតាមភូមិ នៅទីតាំងចាស់ហ្នុងឯង គេចាប់ពួកមេភូមិ តាឆន តាអីទៅវ៉ៃចោល កាលផ្ទះតាឆន នៅប៉ុស្តិ៍ចាស់ហ្នុងហើយ នៅដល់សព្វថ្ងៃ កំសត់ណាស់អូនអើយ ។

វណ្ណៈ : ចុះយាយថែមគាត់មក មីងដែរស្តាប់បានឮគាត់ប្រជុំអីគាត់មានថាម៉េចទេ យាយថែមគាត់នៅឯណា?

គីមរស់ : ទេខ្ញុំ មិនសូវបានប្រជុំ បានអីទេ គាត់មកជុំអីចឹងទៅ យើងមិនសូវបាននៅ ទៅចល័តបាត់ៗទៅ ទៅជាមួយពួកបងយន បងទាវ ចល័តបាត់ៗ ចល័តទៅក្រោម ទៅដល់ទៅកាង៏ កាត់ប្រសាទចុះទៅទន្លេ ចុះទៅអីណ៎ លើករូចទៅ លើកនៅខាងត្បូងភ្នំត្រយូងភ្នំលាភនេះ ទៅនោះគេចាប់យកមនុស្សច្រើនណាស់យកទៅដាក់ អ្នកដែលមានទោសមានពៃ អីពួកនិរតីចាប់ដាក់ភ្នំត្រយូង មូលដ្ឋានចាស់មេកង មេក្រុមអី ពួកពាយ័ព្យណា ។

វណ្ណៈ : បើតាមមីងដឹងទំនប់ត្រពាំងថ្មចាប់ផ្តើមពីឆ្នាំណាទៅ?

គីមរស់ : ៧៧ ហ្នឹងឯង ។

វណ្ណៈ : ពី៧៧ ដល់ឆ្នាំណាធ្វើហើយ?

គីមរស់ ៖ ៧៧ ដល់ ៧៨ ហើយ ។

វណ្ណៈ ៖ ពី៧៧ ដល់ ៧៨ ហើយម៉ែ?

គីមរស់ ៖ ចាំ!

វណ្ណៈ ៖ ទំនប់ធំណាស់ ធ្វើលឿនណាស់ណ៎!

គីមរស់ ៖ មិនលើកយូទេ ។

វណ្ណៈ ៖ ចុះមីងនៅហ្នឹងរហូតដល់ហើយទំនប់ហ្នឹងដែរ?

គីមរស់ ៖ អត់ទេ! ខ្ញុំនៅមិនបានហើយទេ ដូចថាខ្សែត្រៀមវាដាក់បន្តៗគ្នា ។

វណ្ណៈ ៖ អ្នកណាខ្សែត្រៀមណាហើយមុនចប់ដែនការគឺដកមកភូមិវិញ?

គីមរស់ ៖ ដកដាក់កន្លែងផ្សេងទៀត ។

វណ្ណៈ ៖ ដាក់កន្លែងផ្សេងទៀត!

គីមរស់ ៖ ចាំ!

វណ្ណៈ ៖ ចុះមីង...

គីមរស់ ៖ ចប់ខែ៧ ហ្នុងឯង ត្រពាំងថ្មនោះ ចប់ខែ៧ ឆ្នាំ៧៧ហ្នុង មានដល់ឆ្នាំ៧៨ទេ ៧៨បាន លើកនៅឯណោះទៀត ឆ្នាំ៧៨ លើកទំនប់ដង្កៀបក្តាម អាដូវអូលៀសនោះបានឆ្លងទៅ ណោះខាងកើតភ្នំស្រុក បានទៅឯណុះ ទៅឯស្ពានស្រែងណុះ ។

វណ្ណៈ ៖ អីចឹងអាទំនប់ត្រពាំងថ្មលើកតែមួយឆ្នាំទេ?

គីមរស់ ៖ តែមួយឆ្នាំប៉ុណ្ណុះឯង មិនមែនលើកច្រើនទេ នៅឆ្នាំ៧៧នោះឯង ។

វណ្ណៈ ៖ ចុះមីងខាងនិរតីមកបានប៉ុន្មានខែបានគេចាប់ពួកតាវ៉ាល់ ពួកពាយ័ព្យនោះអស់ទៅ?

គីមរស់ ៖ អត់មានយូទេ! មកដល់ភ្លាម គេភ្លាមនោះឯង ។

វណ្ណៈ ៖ មកដល់ចាប់ បានប្រហែលមួយខែទេ?

គីមរស់ ៖ ចាំ! ប្រហែលមួយខែប៉ុណ្ណោះឯង មកដល់គេរៀបគ្នាគេពីបៗដូចថាមកដល់គេជីងក្បាល ម៉ាស៊ីនហើយ គេស្ទាប់ឲ្យតែជីងណា ជីងតែក្បាលម៉ាស៊ីនណាៗ ។

វណ្ណៈ ៖ អីចឹងពួកនិរតីមកបានរយៈពេលប្រហែលមួយខែបានចាប់ពួកពាយ័ព្យទៅអស់មីងណា?

គីមរស់ ៖ ចាំ!

វណ្ណៈ ៖ ហើអីចង់បានបន្តកាប់សម្លាប់ប្រជាជនបន្តបន្ទាប់ទៀត?

គីមរស់ ៖ ចាំ!

វណ្ណៈ ៖ ហើជីវភាពកាន់តែមានបញ្ហាលំបាក!

គីមរស់ ៖ កាន់តែមានបញ្ហាលំបាក ។

វណ្ណៈ ៖ អចឹងរហូត

គីមរស់ ៖ អត់ស៊ីអី អត់រហូតដល់៧៩ ។

វណ្ណៈ ៖ អីចឹង៧៨ មីងថាធ្វើការនៅឯណាវិញ?

គីមរស់ ៖ ឆ្នាំ៧៨ ខ្ញុំមកនៅក្នុងភូមិហ្នឹងឯង ខ្ញុំអីចេះ ៧៨ ខ្ញុំទៅណុះ ចូលឆ្នាំ៧៨ទៅដល់ដង្កៀបក្ដាម ដល់ទៅប្រសាទ ដល់ទៅស្គមខ្លាំង ហីគេបញ្ជូនអ្នកដែលស្គមៗខ្លាំងឲ្យទៅកងវ៉ា ខ្ញុំទៅកងវ៉ាណុះ ។

វណ្ណៈ ៖ អីចឹងមីង៧៨ ចូលភូមិហើយគេបញ្ជូនទៅកងចល័តវិញឬ?

គីមរស់ ៖ ចា៎! ទៅភូមិហើយគេបញ្ជូនទៅកងចល័តវិញ ។

វណ្ណៈ ៖ ម៉េចទៅកងវ៉ាហ្នុងម៉េចដែរ កងវ៉ា?

គីមរស់ ៖ ទៅកងវ៉ា ។

វណ្ណៈ ៖ ទៅធ្វើអី?

គីមរស់ ៖ ទៅកងវ៉ាបាញ់ថ្នាំកប្បាស ។

វណ្ណៈ ៖ ទៅខាងហ្នឹងមិនសូវពិបាកទេឬ?

គីមរស់ ៖ ទេ! មិនសូវពិបាកប៉ុន្មានទេ មានបាយអីហូប នៅហ្នុងណា ។

វណ្ណៈ ៖ បាញ់ថ្នាំកប្បាសនៅឯណា នៅខាង...

គីមរស់ ៖ នៅកងវ៉ា ។

វណ្ណៈ ៖ កងវ៉ានៅស្រុកអីគេ?

គីមរស់ ៖ នៅស្រុកសេរីសោភ័ណ នៅកន្លែងតំបន់ នៅម៉ាដួរភ្នំកងវ៉ាហ្នុង ភូមិពង្រសព្វថ្ងៃត្រង់ហ្នុងឯង ។

វណ្ណៈ ៖ នៅដល់៧៩ ឬ?

គីមរស់ ៖ ចា៎! ដល់៧៩ ។

វណ្ណៈ ៖ ៧៩ រត់យួនម៉ងឬ?

គីមរស់ ៖ ចា៎! ៧៩ រត់មកណោះ រត់មកបានប៉ុន្មានថ្ងៃក៏មកនៅជាមួយពួក អាកំពុងប្រូត កំពុងអត់ខ្លាំង យើងមកដល់ប្រូតហើយ មកដល់ស្រូវទុំនោះណា ។

វណ្ណៈ ៖ ៧៩ រត់មកដល់ភូមិវិញ?

គីមរស់ ៖ ចា៎!

វណ្ណៈ : ភូមិវិញបានបន្ត ការងារធ្វើស្រែចំការទៅ!

គឹមរស់ : ធ្វើស្រែចំការធម្មតាទៅ បានបន្តិចក៏វៀតណាមចូលបណ្ដោយ ។

វណ្ណៈ : វៀតណាមចូលមកមីងនៅក្នុងភូមិរហូតដល់សព្វថ្ងៃទៅ ហើមីងចូលបម្រើការងារខាងមន្ត្រីរាជការ ខាងរដ្ឋកម្ពុជាឆ្នាំណាទៅ?

គឹមរស់ : ខ្ញុំឆ្នាំ៧៩ ។

វណ្ណៈ : ៧៩ ចូលធ្វើគ្រូបង្រៀនឬ?

គឹមរស់ : ចា៎! ៧៩ លោកគ្រូខ្ញុំមក ឯកអគ្គរដ្ឋទូតប្រចាំប្រទេសកូរ៉េ លោកគ្រូ លឹម សំកុល គ្រូខ្ញុំមកឃើញ ក៏ហៅខ្ញុំចូលធ្វើគ្រូទៅ ខ្ញុំមិនចង់ចូលផងកាលហ្នុង ។

វណ្ណៈ : នៅសាលាណា សាលាវិទ្យាល័យ ឬក៏បឋម?

គឹមរស់ : នៅបឋមព្រះនេត្រព្រះ ខ្ញុំមិនចង់ចូលផង ប៉ុនចូលទៅ ទៅឡាក់ទៅអីហ្នឹងគេ យើងរត់ទៅជំរំ ទៅជួញសារ៉ុង ជួញអីគេបាន ២, ៣ ជើងនឹងគេដែរ ទៅបន្ទាយអំពិល ដែលគេវ៉ៃពួកប៉ារ៉ា ពួកអីគេណា បានទៅឃើញមួយជើង ពីរជើងណា ។

វណ្ណៈ : ទៅរកស៊ីបាន២, ៣ ជើងហើយ បានមកធ្វើគ្រូក្នុងឆ្នាំ៧៩ហ្នឹង?

គឹមរស់ : ចា៎! គាត់ឲ្យធ្វើកាលពីខែ៧ ដល់ខែ៩ចូលរៀនណា ខ្ញុំអត់ទៅបង្រៀនទេ ខ្ញុំអាឡើងទៅណុះសិន បានដល់ខែ១០ ខែ១២ បានខ្ញុំទៅរៀននៅបាត់ដំបង ខ្ញុំទៅរៀនហ្នុងខ្ញុំគរុសិស្សខ្ញុំទៅរៀនហ្នុង មុនដំបូងគេហៅចូល ខ្ញុំអត់ចូលទេ ទៅរៀននៅបាត់ដំបង់បានខ្ញុំទៅ ទៅបាត់ដំបង ទៅឆ្នាំ៧៩នោះឯង បានចេញមកធ្វើគ្រូរហូត ។

វណ្ណៈ : បាទ! សព្វថ្ងៃហ្នឹងទៅ!

គឹមរស់ : ចា៎! ធ្វើគ្រូខ្ញុំបង្រៀន កូនសិស្សខ្ញុំតាំងពីមួយថ្នាក់១៥០នាក់ ។

វណ្ណៈ : អូ! ច្រើនមែនទែន!

គឹមរស់ : សិស្សខ្ញុំមានបែងចែក៣ជំនាន់ មានអាតូចមិនទាន់ចេះអីមួយវគ្គ មានអាកណ្ដាលអាទើរសល្មមចាប់បាន ស្រះអា ស្រះអិ មួយវគ្គទៅ ហើមានអាធំល្មមគេចាប់បានច្បាស់ទៅ គេចេះអានចេះអីទៅ ខ្ញុំបង្រៀន៣វគ្គអីចឹង និយាយពីមួយថ្ងៃៗ បង្រៀនសិស្សវល់ល្វាច មិនដែលបានលុយម៉ោង លុយមាំងអីទេ ធ្វើការនេះបម្រើជាតិអស់ហើយខ្ញុំ បម្រើជាតិ ហើយបង្រៀននៅនេះបានដល់ឆ្នាំ៨៤ ថ្នាក់ទី១, ទី២, ទី៣, ទី៤ បង្រៀនទី៤ បាន៣ឆ្នាំ ។ បង្រៀនថ្នាក់ទី១ បានតែមួយឆ្នាំទេខ្ញុំនោះ យើងវាកម្រិតខ្ពស់ណា បង្រៀនថ្នាក់ទី៤ កូនសិស្សខ្ញុំនោះពូកែៗណាស់ ឥឡូវធ្វើអ្នកតូចអ្នកធំអស់ហើយ

អាពីជិនន់មុននោះ ហើយដល់ហ្នឹងទៅគេខ្វះគ្រូអនុវិទ្យាល័យបានគេឲ្យខ្ញុំទៅរៀនបំប៉នគ្រូអនុវិទ្យាល័យ ខ្ញុំមិនចង់ទៅទៀត គេថានៅធ្វើអីបើមិនមានកូនមិនមានចៅ ដូចថាមនុស្សខ្ញុំគេស្រឡាញ់ចូលចិត្តណា នោងឯណាក៏គេអូសទាញខ្ញុំទៅដែរក៏ច្រើន អស់លោកអ្នកធំក៏ច្រើន មិត្តភក្តិក៏ច្រើន ចេះតែអូសទាញខ្ញុំទៅ ខ្ញុំថាមិនទៅទេ កាលនោះខ្ញុំក្រ ខ្ញុំអត់ណា ខ្ញុំថាមិនបានទៅទេ ខ្ញុំក្រ ខ្ញុំរកស្បែកជើងពាក់មិនបាន គាត់ទិញស្បែលជើងឲ្យខ្ញុំពាក់ណា នេះពណ៌ក្រហមអីចេះឯង។ ៨៤ ក៏នាំគ្នាទៅរៀននៅអនុវិទ្យាល័យជប់នោះ ខ្ញុំទៅបង្រៀនកាលហ្នឹងកងពលក៏មានវៀតណាមក៏មាន ខ្ញុំដើរកាត់ភ្នំកាលហ្នឹង ផ្លូវអត់មានដើរស្រួលទេ ខ្សាចផ្ទះ ក៏យើងដើរ បាយអីវេចបាយទៅបង្រៀនណា នេះគ្រាន់តែពោះដេញខ្ញុំប៉ុននេះពស់...ធំណាស់។

វណ្ណៈ : ម៉េចបានដេញ?

គឹមរស់ : ពស់នោះគួរឲ្យខ្លាច។ យើងដើរមក ដូចថាវាស្ងាត់ណា កាលណុះវៀតណាមមកនៅណាហីព្រៃនោះសិស្ស៥ នាក់ កូនសិស្សស្រី។

វណ្ណៈ : អត់អីដែរ?

គឹមរស់ : កូនសិស្សស្រី២នាក់ ខ្ញុំគ្រូម្នាក់៣នាក់ ដើរមកកាត់ព្រៃមក ពីជប់មកព្រៃដីរាប់គីឡូ ហីមានមនុស្សមកពីណា ស្ងាត់ណាស់។

វណ្ណៈ : ហីវា វារកាត់ឬ?

គឹមរស់ : ចា៎! យើងឡើងមកវាមានដើមតំបូកមួយ ដើមកកោះមួយធំប៉ុណ្ណេះឯង វៀតណាមវាទាក់ខ្សែ គេអូ វាណា អើយើងដើរមកវាលុយទឹក លុយអី ព្រៃគៀនៗនោះ វាមានដើរមួយតំបូកយើងឡើងមក វាក៏វាក់មក អីចេះឯងវាក់គ្នានោះ វាក៏មកពីលិចមក វាទៅពីលិច យើងដើរមកពីជើងអីចេះ ដើរមកផ្ទះ ម៉ោង១១។

វណ្ណៈ : ថ្ងៃត្រង់ឬ?

គឹមរស់ : ចា៎! វាក់មក ដល់វាឃើញយើង ក៏បើកដាក់មក ដេញ ខ្ញុំក៏រត់បកមកក្រោយវិញ ហើយក៏មិនហានដើរ ខ្ញុំវង់ទៅឡើងជប់...

វណ្ណៈ : វាដេញតែមួយភ្លែត វាឈប់ដែរ?

គឹមរស់ : ចា៎! ដេញទៅ វាដេញតែមួយភ្លែតទៅ យើងរត់ប្រហែលតែពីនេះទៅដល់នោះ វាមានខុកវាផាកទៅខាងកើតឆ្ពងទៅអីចេះ បើសិនជាវាដេញតាមឲ្យជាប់ផាប់អស់តែទាំងអស់។ ភ័យអើយរុះសក់អស់ខ្លះៗ ក៏បានទៅបង្រៀន បង្រៀនដើរឡើងវេចបាយទៅរហូតដល់

ឆ្នាំ៩៣ បានពួកអប់រំខេត្តចុះមក ខ្ញុំក៏ចេះតែនិយាយពីការលំបាករបស់ខ្ញុំនៅឆ្ងាយមក បង្រៀនឆ្ងាយ មកបង្រៀនស្អី១ទៅ បានលោក ពីន ខញ្ញ៉ា ប្រធានមន្ទីរ គាត់បង្កើតសាលាអនុវិទ្យាល័យឲ្យខ្ញុំឆ្នាំ៩៣ហ្នុង កាលនោះខ្ញុំជានាយករងទេ មិនទាន់បានជានាយការទេ មានលោក គាន់ វំឈួយ សព្វថ្ងៃគាត់រីត្រែតទៅ បានខ្ញុំឡើងនាយការ រហូតដល់សព្វថ្ងៃនេះ និយាយពីការងារខ្ញុំធ្វើការងារខ្ញុំស្មោះត្រង់ខ្ញុំស្រឡាញ់ការងារខ្ញុំណាស់ ។

វណ្ណៈ : អនុវិទ្យាល័យអីគេមីង?

គឹមរស់ : អមុវិទ្យាល័យព្រះនេត្រព្រះ ។ ស្រឡាញ់ការងារណាស់ មានមនសិការបម្រើជាតិ បម្រើការងារ ហើយទៅបង្រៀនទៅដប់នោះមួយសប្តាហ៍២៤ម៉ោងបង្រៀន មួយ៨ម៉ោង វាល់១ល្ងាច ខ្ញុំហូបបាយកូនសិស្សណា ខ្ញុំប្រាប់កូនសិស្សខ្ញុំថា អាពុន អើយ គ្នាមិនទៅផ្ទះទេ នៅញ៉ាំបាយនៅនេះឯង វាយកបាយមកទាំងស្រាក់១ទៅឲ្យ ពងទា សាច់ជ្រូក សាច់អីធារម្ហូបឆ្ងាយ១ ចុះគេអ្នកមាននោះ គេយកបាយទៅឲ្យហូប កូនសិស្សខ្ញុំ យកបានទៅឲ្យហូបទាំងស្រាក់១ គ្រូ១នៅនោះ ថ្ងៃណាគាត់មិនទៅផ្ទះ គាត់ក៏នៅហូបបាយជាមួយខ្ញុំដែរ កាលនោះមិនសូវមានណាទៅដេញដើងគ្នាចង់មាន ចង់បានអីទេ អត់ទេ នៅក្រកិក្រកៀរណាចង់បានចង់អីធ្វើអីទេ នៅកិកៀរគ្នានៅសាលាហ្នឹងឯង ហូបបាយកូនសិសឲ្យក៏ហូបនៅនោះទៅ ហីបានដល់ខ្ញុំមកនៅនេះបានបែកគំនិតចេះចង់មានចង់បាន មានរបបរកខ្វះអីការងារខ្វះណា កាលមុនស្រឡាញ់តែការងារអើយ ខ្ញុំកាលមុនមិនមានប្តីមិនមានកូនការងារអើយការងារតែប៉ុណ្ណឹងទៅ ហីម៉ែឪខ្ញុំគាត់ចេះតែនេះទៅ មិនមានគំនិតថាចង់មានចង់បានអីទេ អត់សោះ ។

វណ្ណៈ : អ៊ិចឹងមីងខ្ញុំសួរតែមួយសំណួរទៀតទេ ទាក់ទងរឿងតុលាការបច្ចុប្បន្នមីងដឹងខ្វះដែរ រឿងកាត់ទោស រឿងអីហ្នឹង ចុះមីងយល់ម៉េចដែររឿងកាត់ទោសមេដឹកនាំខ្មែរក្រហមជារឿងត្រឹមត្រូវ បើតាមយោបល់របស់មីង?

គឹមរស់ : បើតាមយោបល់ខ្ញុំ យើងជាអ្នកពុទ្ធសាសនា ថាមានកម្មមានពារ ថាប៉ុណ្ណឹងទៅ យើងមិនចង់ចងកម្មចងពារតទៅទៀតណា ដោយសារចាំនិយាយរក ស្រាវជ្រាវរក រកឬសរកគល់ ឧទាហរណ៍ដូចថាមិត្ត ហឿន មិត្តសាត ដូចថាអ្នកសម្លាប់ផ្ទាល់ដៃអីចឹង យើងចង់ទោសងសឹក ចាបវាយកទៅវ៉ៃចោល ដូចថាយើងធ្វើអីចឹងទៅកម្មពាចេះតែត អីចឹងខ្ញុំអាចសន្និដ្ឋានថាធ្វើប៉ុណ្ណឹងដូចថាសមហេតុផលដែរ ឲ្យវាតាមកម្មតាមពារទៅចុះ មិនថាជាតិមុខក្រោយអី នេះឯងធ្វើខ្លួនអ្នកឯង អ្នកឯងទៅធ្វើកម្មធ្វើពារខ្លួនឯងទៅ អាហ្នឹងចិត្ត

អ្នកសាសនាណា បើចិត្តជាអ្នកខ្លាំង អ្នកក្តៅប៉ុណ្ណឹងមិនទាន់សមហេតុផលទេ ចង់ថាអ្នកឯង វ៉ៃខ្ញុំ ខ្ញុំវ៉ៃអ្នកឯងវិញអីចឹងណា បើ ក វ៉ៃខ្ញុំ ខ្ញុំចង់វ៉ៃ ក វិញឲ្យងាប់ បើខ្ញុំគេ ធ្វើបាប កំសត់នោះវាអស្ចារ្យហើយ ខ្ញុំនិយាយទៅនិយាយអត់អស់ផង កន្លែងទាក់ទងគ្នា កន្លែងថា ជាប់ប្រវត្តិកូនសិស្សនោះណា ។

វណ្ណៈ : បាទ! ម៉េចទៅមីង?

គឹមរស់ : នៅកូនខ្លែងថែលថាមើលសិល្បៈជួបគ្នា ជួបប្រវត្តិកូនសិស្ស ហីគេស្រាវជ្រាវប្រវត្តិកូន សិស្ស ខ្ញុំជិត សេអុីអាគេយកទៅវ៉ៃចោលហើយខ្ញុំ ។

វណ្ណៈ : អីចឹង?

គឹមរស់ : ចា៎!

វណ្ណៈ : ម៉េចបានរួចខ្លួន?

គឹមរស់ : ដោយសារតា សំអាត ហ្នឹង ។

វណ្ណៈ : អូ! តា សំអាត!

គឹមរស់ : តា សំ អាតនេះអីចេះ ខ្ញុំទៅនៅចល័តឯស្ថានកម្ម ដូចថាយើងអ្នករៀនអ្នកសូត្រ ខ្ញុំ រៀននៅស្វាយ ប៉ុនខ្ញុំមានបងខ្ញុំនៅធ្វើពេទ្យនៅបាត់ដំបងនៅជាមួយគាត់ ចែខ្ញុំគាត់ដុកទ័រ ណាដុទ័រឆ្នប ដូចថាផ្ទះសម្បែងគាត់មានសន្ទាប់ផ្ទាប់ ផ្ទះគេដាំបាយខ្សែភ្លើង គេដាំទឹកដាំ អីណា ខ្ញុំកាលណុះផ្ទះចែខ្ញុំ ដូចថាខ្ញុំមានរបៀបរបប ដាំទឹក ដាំអី គេញ៉ាំទឹកក្តៅ ទឹកអី គេលាងកែវ លាងអី លាងចាន លាងបំពង់ទឹកក្តៅអី ដាក់កំភ្លេរ ។ តាសំអាត នោះខ្ញុំទៅនៅជាមួយយាយខុន នោះប្រធានភូមិខាងអីណុះ ឯស្ថានកម្មណុះ ខ្ញុំនៅជាមួយ គាត់ ស្រាប់តែយើងខស្សរាហ៍ណា យើងឃើញគាត់មនុស្សចាស់អីចឹងខ្ញុំក៏ក្រោកបោសផ្ទះ ជូតផ្ទះ ជូតអីខ្ញុំដាំទឹក ដាំអី ដាក់ធុងទឹកក្តៅ ដាក់កែវដាក់អីគ្រប់ឲ្យគាត់ទៅបោសស្អាត អីស្អាតទៅ គាត់ឃើញសកម្មភាពយើងខស្សរាហ៍ណា គាត់ស្គាល់ខ្ញុំច្បាស់តាសំអាតនោះណា ដល់ពេលគេយកខ្ញុំទៅវ៉ៃចោល ខ្ញុំចេញពីចល័តមកហើយ បកពីណុះមកវិញហើយ នោះ ហើយដែលចេញចៃខ្លាំងនោះណា ។

វណ្ណៈ : មីងបានរួចខ្លួនដោយសារឈ្មោះអាតហ្នុងជួយ?

គឹមរស់ : ចា៎! ដូចថាខ្ញុំយើងធ្វើទៅគេតាមដាននោះណា យើងកូនសិស្សកូនអីទៅ ដូចថាវាដាន់ ដំណាក់នោះណា ទៅនៅយូដាន់ដំណាក់ហើយ បងបឿន បងផន នេះ គាត់នាំខ្ញុំទៅវាស់ដី យើង អត់ដឹងថាគេយកទៅវ៉ៃចោលទេ អត់ដឹងសោះ គាត់នាំខ្ញុំទៅវាស់ដី អត់ដឹងថា

គេយកទៅ វៃចោលទេ អត់ដឹងសោះ គាត់ថាយកទៅវាស់ដី យើងដល់ អាស្តាន ...ព្រៃមាន់នោះ ក៏គេនាំចុះ ទៅព្រៃខ្លុង ខ្ញុំក៏ទៅហ្នឹងគេទៅដល់ល្ងាចម៉ោង៥, ៥កន្លះអី ឈរេរេរានោះ ទៅមិនទៅយើងបេះតែដើរ គេដើរទៅមុន ដល់ប្រហែលអីណុះយើងក៏នៅ ក្រោយនេះឯង នៅកន្លែងដីភក់ៗ ។

វណ្ណៈ : មីងនៅតែឯង?

គីមរស់ : ទេ! ៥, ៦ នាក់ ៧,៨ នាក់ ដែលគេនាំយើងទៅណា ខ្ញុំមានស្រីៗ២នាក់ ហើយ គេមានប្រុសៗ ស្រីៗមានបងបឿន បងផន ទៅ ប្រុសៗ ៤,៥,៦ នាក់ បួន ១០នាក់ទាំងខ្ញុំ ទៅៗខ្ញុំអត់ដឹងទេ ប៉ុនគេមិនបានចងមិនបានអីទេ ដើរទៅណា ។

វណ្ណៈ : កាលហ្នឹងនិរតីអត់ទាន់ចូលមកទេ?

គីមរស់ : ចាំ! នៅ និរតីអត់ទាន់ចូលមកទេ កាលខ្ញុំគេយកទៅ គេថាយកទៅឡើងបេះស្លឹកដក់មាន ជីវិតខ្ញុំ តាំងពីកើតមកមានដែរបានទៅណា ទៅក៏ឃើញអាស្លឹកដក់នោះមានដែលបានទៅ ណា ព្រៃខ្លុង ព្រៃត្បែងនោះក៏កាយទៅស្លឹកដក់ ក៏បេះវិចទៅក៏បានកូនក្រមា ស្រាប់តែ មានបរ ទេះចូលមក ពួកនោះគេដើរពីត្បូងមកណុះ ស្រាប់តែមានអានិរសាបងសំអាតហ្នឹង អាម៉ូតូ សេអិលគេនោះ អាខៀវ ជិះម៉ូតូសេអិលមកបឹមៗអីចឹងទៅឃើញខ្ញុំស្គាល់ បងរស់ៗ ឯណាបងបឿន ហីបងផន ខ្ញុំថានោះបងបឿន បងផន ទៅនៅនោះ បានអាសឿមនោះវា ថាបងរស់ឯងសំណាងហើយ បងឯងទៅវិញចុះ ខ្ញុំអត់ដឹងទេ ដឹងតែ គេថាសំណាងហើយ គេថាបងឯងទៅវិញទៅ ខ្ញុំក៏មិនដឹងដែរ ស្រាប់ដល់គេថាបងឯងទៅ វិញទៅ ខ្ញុំក៏ត្រឡប់ អត់ទាន់បានត្រឡប់មកវិញទេ ទៅសឿម ក៏សួររកថាឯណាបងបឿន ហីបងផន ថាណុះបងបឿន បងផន នៅណុះ បាន សឿមគេថា បងឯងទៅវិញទៅ បងឯងបាន ទៅវិញហើយបងឯង បានទៅវិញហើយ ខ្ញុំមិនដឹងទេ ។

វណ្ណៈ : អត់ដឹងថាគេយកទៅវៃចោលទេ?

គីមរស់ : អត់ដឹងទេ! ស្រាប់តែគេទៅតាមមក បានជាឲ្យទៅតាមខ្ញុំនេះតាសំអាតគាត់ទៅដល់កន្លែង ចល័តនោះ ទៅដល់គាត់ទៅសួររកមេដឹកនាំឯណោះ សួររកបងបឿន ហីបងផន នេះណា ថាមិត្តបឿន មិត្តផនទៅណាហើយ តាចាមហ្នឹងគាត់ប្រធានសហករណ៍នៅស្រះកើត គាត់ ថាមិត្តបឿន និងមិត្តផន យកមិត្តរស់ទៅវៃចោល ។

វណ្ណៈ : អីចឹងពេលយកទៅអត់បានរាយការណ៍ទៅតាអាត់ទេ?

គីមរស់ : ទេ! ទៅគាសំអាតគាត់ក៏ដឹងគាត់ក៏ដឹង គាត់ថា គាត់ភ្ញាក់ព្រឹកភ្លាមនោះ គាត់ចាប់អារម្មណ៍ណា ដូចថាសកម្មភាពយើងដែលធ្វើបម្រើគាត់អីទៅ គាត់ថាចុះមីងរស់វាម៉េច តាចាមនោះគាត់រាយការណ៍ប្រាប់ មីរស់មានម៉េចវា គ្មានរឿងស្អីទេវានោះទេ ប៉ុន្តែ គ្រាន់តែគេចាប់បណ្តាញគេថា សេអ៊ីអាអីឯណា ប៉ុនមិនមានសមត្ថភាពអីផងនោះ គេរាយការណ៍ថាអីចេះទៅណា ខ្ញុំដឹងខ្លួនមកវិញហើយណា តាចាម គាត់និយាយប្រាប់ខ្ញុំណា វាមានអ្នកល្អមានអ្នកអាក្រក់ អីចឹងហើយបានតាសំអាតនោះថា អាសឿមទៅតាមយកមកវិញ ។

វណ្ណៈ : ឆ្នាំណា ឆ្នាំហ្នុង?

គីមរស់ : ចុងឆ្នាំ ៧៧ ខ្ញុំមកពីកូនខ្វែងហើយនោះ អាដែងចេញចៃចេញអីនោះក៏មកមុជទឹកនៅហ្នឹងព្រៃមាន់នេះ មកមុជទឹកបេះស្លឹកអញ្ចាញកក់ ជ្រុះចៃមកទាំងក្តាប់ៗ ។

វណ្ណៈ : អីចឹងបានរួចខ្លួនទៅ កុំអីស្លាប់បាត់?

គីមរស់ : បានតាសំអាត គាត់ព្រួអីចឹងបានគាត់ថាហ្ហែ! មិនបានទេ យកវាមកវិញៗ មីរស់ យកវាមកវិញ បានក៏ឲ្យអាសឿមទៅតាមបងបឿន បងផងឲ្យយកខ្ញុំមកវិញ បានរស់នេះចាប់ពីពេលនោះមកខ្ញុំបានរស់រហូតមក តាមអំពើល្អ សកម្មភាពដែលយើងបានធ្វើ ដោយសារការខស្បាហ៍ព្យាយាម អីចឹងហើយបានជាខ្ញុំតែងនិយាយប្រាប់កូនចៅខ្ញុំ ខ្ញុំពន្យល់អំពីសកម្មភាពខស្បាហ៍ ការងារដែលយើងខស្បាហ៍ មនសិការដែលយើងធ្វើការ ងារណាពេលណាយើងខ្ជិលច្រអូសគ្មានអ្នកណាទៅអាណិតយើងទេ សកម្មភាពដែលយើងធ្វើហ្នឹងគេមានចងចាំតើស ថាអូមនុស្សនេះវាខស្បាហ៍ វារអែង វាអីទៅ ទោះយ៉ាងណា ក៏មានអនុស្សាវរីយ៍នឹកឃើញជាប់មកជាមួយដែរ ដោយសារមាននិស្ស័យ ឬមួយក៏អាយុ វាមិនទាន់អស់មិនដឹង...សើច ។

វណ្ណៈ : បាទ! ជួនកាលយើងមានកំហុសតិចតួចមែន ប៉ុន្តែយើងការងារសកម្ម គេអាចថាមនុស្សហ្នឹងមានកំហុសតិចតួចទេ អាចទុកសិនទៅ មនុស្សហ្នឹងសកម្មដែរអីចឹងទៅ អីចឹងបានថាយើងខស្បាហ៍ហ្នឹងក៏វាមានជោគជ័យសម្រាប់ជីវិតយើងដែរ ។ អីចឹងខ្ញុំអរគុណមីងច្រើនហើយណាមីងណា ដែលបានផ្តល់បទសម្ភាសន៍ ហើយចំណាយពេលអស់ជាច្រើនដែរ មួយម៉ោងហើយ អរគុណហើយណាមីង ។

គីមរស់ : ចា៎!

«ចប់»